# មជ្ឈមណ្ឌលដើម្បីសន្តិភាព និង អភិវឌ្ឍន៍

# វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

Centre for Peace and Development (CPD)
Cambodia Development Resource Institute (CDRI)

## កំណត់ហេតុកិច្ចប្រជុំខប់សែលប្រ៉ូម តំបន់ទី ៧

## យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ដំណាក់កាលទី ២

**ថ្ងៃអង្គារ៍ ទី០៦ ខែកុម្ភៈ ឆ្នាំ២០០៧**

**ខេត្តសៀមរាប**

**ខប់សែល ដំណាក់កាលទី ២**

**COPCEL Phase II**

*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

**United Nations Development Programme (UNDP)**

## របៀបវារៈនៃកិច្ចប្រជុំ

០១. ចំណាប់អារម្មណ៍ស្វាគមន៍ដោយ លោក **ឡារី ស្រ្តេន្ទ** (Larry Strange) នាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

០២. បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ម (COPCELPROM) ដោយលោក **ឱក សេរី សោភ័ក្តិ** ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការខប់សែល នៃវិទ្យាស្ថាន CDRI

០៣. ស្ថានភាពទូទៅ នៃការរៀបចំការបោះឆ្នោតថ្លែងដោយលោក **នឹម វ៉ាន់សំ** ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោត ខេត្តសៀមរាប

០៤. មតិរបស់អ្នកចូលរួមដែលបង្ហាញអំពីការប្រឈមទាំងឡាយក្នុងយន្តការរៀបចំការបោះឆ្នោតក្នុងបរិបទខេត្តសៀមរាប

០៥. សេចក្តីផ្សេងៗ

### ០១. ចំណាប់អារម្មណ៍ស្វាគមន៍ដោយ លោក ឡារី ស្រ្តេន្ទ (Larry Strange) នាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

លោក **ឡារី ស្រ្តេន្ទ** នាយកប្រតិបត្តិ នៃវិទ្យាស្ថាន បណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ក្នុងនាមជានាយកវិទ្យាស្ថាន CDRI លោកមានសេចក្តីរីករាយណាស់ ដែលបានចូលរួមនៅក្នុង ខប់សែលប្រ៉ម នៅខេត្តសៀមរាបនេះ លោកសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះសមាជិកអង្គប្រជុំដែលបានចូលរួមក្នុងអង្គប្រជុំនេះ ។ ចាប់តាំងពីលោកបានចូលធ្វើការនៅក្នុងប្រទេសកម្ពុជាអស់រយះពេលជាង៣ឆ្នាំកន្លងមកនេះ គឺលោកបានមកទស្សនកិច្ចនៅក្នុងទឹកដីខេត្តសៀមរាបដ៏រុងរឿងនេះជាច្រើនដង កន្លងមកហើយ ។ លោកបានជំរាបជូនអង្គប្រជុំថា ខប់សែល បានរៀបចំកិច្ចប្រជុំជាប្រចាំទាំងថ្នាក់ជាតិ និងថ្នាក់ខេត្តដើម្បីលើកឡើងនូវបញ្ហាងទៀត១ជុំវិញការងារបោះឆ្នោតក្នុងគោលបំណងធ្វើយ៉ាងណាអាចទប់ស្កាត់ និងដោះស្រាយទាំងអស់គ្នានូវរាល់ទំនាស់ដែលអាចកើតមាន ។ កន្លងមកយើងបានរៀបចំកិច្ចប្រជុំថ្នាក់ខេត្តជាច្រើនរហូតមកដល់ពេលនេះបានជាង២០ខេត្តមកហើយ នៅក្នុងកិច្ចប្រជុំខប់សែលប្រ៉ម នីមួយៗវិទ្យាស្ថាន CDRI មានសេចក្តីរីករាយ និងមោទនៈភាពជាទីបំផុតដែលបានឃើញការចូលរួមយ៉ាងច្រើនកុះករពីសំណាក់គ្រប់ភាគីពាក់ព័ន្ធនានាជុំវិញការងារបោះឆ្នោត ហើយបានលើកនូវបញ្ហានានាយកមកពិភាក្សាយ៉ាងផុលផុស និងសកម្មជាពិសេសប្រកបដោយការគោរពនិងយោគយល់គ្នា ។

ឆ្លៀតក្នុងឱកាសនេះ លោក សូមថ្លែងអំណរគុណចំពោះក្រសួងមហាផ្ទៃ ជាពិសេស ឯកឧត្តម **ស៊ូ ភិរិន** ដែលជាអភិបាលខេត្តសៀមរាបដែលបានអនុញ្ញាតិឱ្យខប់សែលបានដំណើរការ និងធ្វើការរៀបចំកិច្ចប្រជុំនៅពេលនេះ ។ ទន្ទឹមនឹងនេះ លោក សូមថ្លែងអំណរគុណដល់លោកប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោត ខេត្តសៀមរាបដែលបានគាំទ្រចំពោះវិទ្យាស្ថាន CDRI ។ លោក ក៏សូមថ្លែងអំណរគុណផងដែរដល់អង្គប្រជុំទាំងអស់ដែលបានចូលរួមក្នុងកិច្ចប្រជុំនេះ ជាពិសេសតំណាងក្រសួងមហាផ្ទៃ មានដូចជា ស្នងការនគរបាលខេត្ត អាជ្ញាធរខេត្ត អភិបាលស្រុក អភិបាលរងស្រុក ក្រុមប្រឹក្សាឃុំសង្កាត់ អង្គការសង្គមស៊ីវិល និងតំណាងគណបក្សនយោបាយទាំងអស់ ។

វិទ្យាស្ថាន CDRI គឺជាស្ថានប័នសិក្សាស្រាវជ្រាវឯករាជ្យទៅលើគោលនយោបាយអភិវឌ្ឍន៍នានាដើម្បីធ្វើឱ្យការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជាប្រកបដោយចិរភាព ក៏ប៉ុន្តែវិទ្យាស្ថាន CDRI បានមើលឃើញ និងចាត់ទុកថាយន្តការខប់សែលជាយន្តការមួយ

គន្លឹះ និងសំខាន់បំផុតក្នុងការជំរុញឱ្យមានលទ្ធិប្រជាធិបតេយ្យ និងជំរុញឱ្យដំណើរការបោះឆ្នោតប្រកបដោយតម្លាភាព ។ ដើម្បីទទួលបានការអភិវឌ្ឍន៍នានា គឺយើងត្រូវធានាឱ្យបាននូវសន្តិភាពនិងលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ។ វិទ្យាស្ថាន CDRI យល់ថាដំណើរការបោះឆ្នោត គឺជាក្បាលម៉ាស៊ីនមួយដែលឆ្ពោះទៅរកការកសាងលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ហើយយន្តការ ខប់សែល គឺជាយន្តការតែមួយនៅប្រទេសកម្ពុជាដែលបានរៀបចំឡើងក្នុងគោលបំណងធ្វើឱ្យកាន់តែប្រសើរឡើងក្នុងដំណើរការបោះឆ្នោតនៅកម្ពុជា ។

លោក បានជូនពរឱ្យការប្រជុំនេះប្រកបដោយផ្លែផ្កាត្រង់ទៅត្រង់មក និងមានការជឿទុកចិត្តគ្នាជាទីបំផុត ។

អ្នកស្រី **Margie Cook** តំណាង UNDP បានមានប្រសាសន៍ថា នេះជាលើទី២ហើយដែលអ្នកស្រីបានមកក្នុងទឹកដីខេត្តសៀមរាបបន្ទាប់ពីបានមកទស្សនកិច្ចម្តងជាមួយនឹងម្តាយរបស់អ្នកស្រី ហើយជាកិត្តិយសនិងមានសេចក្តីរីករាយជាទីបំផុតដែលបានចូលរួមនៅក្នុងកិច្ចប្រជុំខប់សែលប្រ៉ុមនៅខេត្តសៀមរាបនេះ ។ ឆ្លៀតឱកាសក្នុងព្រឹកនេះអ្នកស្រីសូមជំរាបជូនអង្គប្រជុំថា កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ UNDP មានសេចក្តីរីករាយណាស់ដែលមានឱកាសគាំទ្រចំពោះដំណើរការនៃការរៀបចំការបោះឆ្នោត ហើយ UNDP បានគាំទ្រយ៉ាងពេញទំហឹងចំពោះគណកម្មាការជាតិរៀបចំការបោះឆ្នោតទៅលើការបណ្តុះបណ្តាផ្នែកបច្ចេកទេស, ផ្នែកផ្លូវច្បាប់ និងសារពត៌មាន ។ UNDP ក៏បានគាំទ្រចំពោះបណ្តាអង្គការសង្គមស៊ីវិលឯទៀត។ដែលធ្វើការពាក់ពន្ធ័ការបោះឆ្នោតសំដៅជំរុញឱ្យដំណើរការរៀបចំការបោះឆ្នោតនេះប្រព្រឹត្តទៅបានដោយប្រសើរ ។ អ្នកស្រីបានជំរាបថា ចំពោះការបោះឆ្នោតនេះប្រទេសដ៏ទៃទៀត។ក៏អនុវត្តដូចនៅក្នុងប្រទេសកម្ពុជាយើងនេះដែរ ដូច្នេះដំណើរការនៃការរៀបចំការបោះឆ្នោតនៅប្រទេសកម្ពុជារហូតមកដល់ពេលនេះ មិនមែនជារឿងចំឡែកពីគេនោះទេព្រោះនៅពេលរៀបចំការបោះឆ្នោតម្តង។តែងតែកើតមានឡើងនូវរឿងរ៉ាវឯទៀត។ ប៉ុន្តែអ្វីដែលយើងគួរយកចិត្តទុកដាក់បំផុតនោះ គឺនៅក្នុងដំណើរការនៃការរៀបចំនិមួយ។យើងត្រូវរក្សាឱ្យបាននូវ តំលៃ និងស្ថេរភាពផ្នែកនយោបាយព្រមទាំងផ្នែកផ្សេង។ទៀតសំដៅធ្វើឱ្យប្រទេសរបស់យើងមានការអភិវឌ្ឍន៍ នោះហើយជាសារៈសំខាន់នៃដំណើរការនៃការរៀបចំរបស់គណកម្មាជាតិរៀបចំការបោះឆ្នោត ។ នៅក្នុងព្រឹកនេះអ្នកស្រីសូមលើកយកចំណុច ៤មកបង្ហាញ ជូនអង្គប្រជុំ:

**ទី ១** ការចូលរួមពីគ្រប់ស្ថាប័ននិងភាគីពាក់ព័ន្ធនៅក្នុងដំណើរការនៃការរៀបចំការបោះឆ្នោត ជាពិសេសជាក់ស្តែងនៅព្រឹកនេះមានគ្រប់ភាគីពាក់ពន្ឋ័ឯទៀត។តាំងពីអាជ្ញាធរ គណបក្សនយោបាយ អង្គការសង្គមស៊ីវិលនានា ដែលពាក់ពន្ធ័នៅក្នុងរឿងនយោបាយដើម្បីចូលរួមទាំងអស់គ្នា ហើយបច្ចុប្បន្ននេះយើងឃើញមានការកើនឡើងនូវការចូលរួមពីតំណាង គ្រប់ភាគីឯទៀត។ជាពិសេសគឺយើងឃើញមានតាំងពីតំណាងខាងអង្គការជនពិការឬតំណាងអង្គការឯទៀត។នៅក្នុងដំណើរការនៃការរៀបចំការបោះឆ្នោតនេះ ។

**ទី ២** ដែលអ្នកស្រីបានជំរាបជូននោះគឺស្តីអំពីដំណើរការនៃការកសាងនូវវប្បធម៌ជជែកពិភាក្សាគ្នាព្រោះរឿងរ៉ាវជាច្រើនដូចជាការខ្វែងគំនិតគ្នា ពាក្យចចាមអារាមផ្សេង។តែងតែកើតមានជាប្រចាំ ដូចនេះវិធីដ៏ល្អនោះគឺយើងត្រូវយករឿងទាំងអស់នេះមកពិភាក្សាទល់មុខគ្នា។

**ទី៣** ការចូលរួមកសាងនូវវប្បធម៌ពិភាក្សានេះសំដៅបង្ការឬទប់ស្កាត់នូវបញ្ហាដែលអាចកើតមានឡើងជុំវិញការងារបោះឆ្នោត ហើយការចូលរួមក្នុងការពិភាក្សានេះទីបំផុតធ្វើឱ្យយើងអាចដោះស្រាយនូវបញ្ហានានាជុំវិញការងារបោះឆ្នោតបាន ម្យ៉ាងទៀតយើងថែមទាំងអាចធ្វើឱ្យដំណើរ ការនៃការរៀបចំការបោះឆ្នោតនេះប្រព្រឹត្តទៅបានល្អប្រសើរឡើងទៀតផង ព្រោះកាលណាយើងគ្រប់គ្នាកាន់តែយល់ដឹងច្បាស់អំពី និតិវិធីនិងច្បាប់ឯទៀត។ជុំវិញការងារបោះឆ្នោតនោះ នឹងធ្វើឱ្យដំណើរការនៃការរៀបចំការបោះឆ្នោតប្រព្រឹត្តទៅប្រកបទៅដោយសន្តិភាព នៅពេលដែលយើងទាំងអស់គ្នាបានជ្រាបច្បាស់នូវពតិមានទាំងអស់នេះ ។

ឆ្លៀតក្នុងឱកាសនេះអ្នកស្រីសូមកោតសរសើរ ចំពោះវិទ្យាស្ថាន CDRI ដែលបានផ្តួចផ្តើមគំនិតរៀបចំកម្មវិធីថ្មីមួយស្តីអំពីការត្រួតពិនិត្យនូវរាល់សារព័ត៌មាន-កាសែត ។ នេះជាកម្មវិធីដែលទើបនឹងចាប់អនុវត្តថ្មីៗនេះទេ គឺវិទ្យាស្ថាន CDRI បានផ្ញើព័ត៌មានតាមរយៈអ៊ីមែលជូនគ្រប់ភាគីពាក់ពន្ធ័ឯទៀតៗនៅក្នុងរឿងបោះឆ្នោតនេះ ដើម្បីឱ្យជ្រាបច្បាស់អំពីដំណើរការនៃការបោះឆ្នោតនៅក្នុងប្រទេសកម្ពុជាក្នុងគោលបំណងរកនូវគន្លឹះដើម្បីដោះស្រាយនិងទប់ស្កាត់នូវបញ្ហាផ្សេងៗដែលអាចកើតមាន ។ ចំពោះកម្មវិធីនេះ គឺផ្តួចផ្តើមពីវិទ្យាស្ថាន CDRI ដែលជាកម្មវិធីមួយអព្យាក្រឹតពុំមានការលំអៀងទៅរកគណបក្សនយោបាយណាមួយទេ ហើយសេវានេះវិទ្យាស្ថាន CDRI ផ្តល់ជូនដោយមិនគិតថ្លៃ ដូច្នេះប្រសិនបើអស់លោក លោកស្រី ចាប់អារម្មណ៍អាចទំនាក់ទំនងដើម្បីទទួលបាននូវសេវាព័ត៌មាននេះបន្ថែមទៀតជារៀងរាល់ថ្ងៃ ។

ចំណុចចុងក្រោយដែលអ្នកស្រីសូមជំរាបជូនអង្គប្រជុំ គឺថាយើងមានមោទនៈភាពជាទីបំផុតដែល ខប់សែល ឥលូវនេះមិនត្រឹមតែទទួលស្គាល់តែថ្នាក់ជាតិទេ ក៏ប៉ុន្តែ ខប់សែល ថែមទាំងត្រូវបានគេទទួលស្គាល់ជាអន្តរជាតិទៀតថា វាជាយន្តការមួយដែលប្រកបទៅដោយប្រសិទ្ធិភាពក្នុងការចូលរួមទប់ស្កាត់ និងជួយជុំរុញឱ្យដំណើរការនៃការរៀបចំការបោះឆ្នោតនេះ ប្រព្រឹត្តទៅបានល្អ ។ កាលពីសប្តាហ៍មុនអ្នកស្រីបានទទួលនូវសំណើរមួយពីប្រទេសជាមិត្តនៅក្នុងតំបន់អាស៊ីដែលប្រទេសគាត់មានស្ថានភាព ប្រហាក់ប្រហែលគ្នា នឹងប្រទេសយើងដែលគាត់មានគោលបំណង នឹងរៀបចំការបោះឆ្នោតថ្នាក់ជាតិ ហើយគាត់ចង់ដឹងពីសាវតា និងរបាយការណ៍ របស់យន្តការខប់សែលនីមួយៗដែលបានរៀបចំជាប្រចាំនៅក្នុងទីក្រុងភ្នំពេញ ក៏ដូចជា នៅតាមបណ្តាខេត្តផ្សេងៗផងដែរ ដើម្បីគាត់អាចរៀនសូត្រ និងស្វែងយល់បានកាន់តែច្បាស់ ។ អ្នកស្រីក៏មានប្រសាសន៍ផងដែរថា អ្វីដែលជុំរុញឱ្យ ខប់សែល ទទួលបានជោគជ័យនោះ គឺជាការចូលរួមរបស់អស់លោក លោកស្រី ក្នុងការលើកឡើងនូវមតិយោបល់ឬក៏បញ្ហាប្រឈមផ្សេងៗ ដែលកើតមាននៅក្នុងថ្នាក់ ខេត្ត-ក្រុង និងថ្នាក់ជាតិ ហើយនេះជាជោគជ័យមួយដ៏សំខាន់ណាស់សំរាប់ប្រទេសកម្ពុជាយើង ។

ជាទីបញ្ចប់អ្នកស្រីបានថ្លែងអំណរគុណដល់អង្គប្រជុំ និងជូនពរឱ្យការពិភាក្សា និងការលើកឡើងនៅព្រឹកនេះប្រកបទៅដោយផ្លែផ្កា និងមានការយោគយល់គ្នា ។

## ០២. **បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ូម (COPCELPROM) ដោយលោក ខ្វិក សេរីសោភ័ក្ត្រ ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការខប់សែល នៃវិទ្យាស្ថាន CDRI**

ដោយខ្លួនលោកផ្ទាល់ធ្លាប់ឆ្លងកាត់ធ្វើការតស៊ូនៅជាយដែនជាង១១ឆ្នាំ និងបានឃើញនូវភាពទុក្ខសោកវេទនារបស់ប្រជាពលរដ្ឋយើង លោកបានគិតថា យើងមិនគួរបំភ្លេចនូវប្រវត្តិដ៏ជូចត់នេះទេ គឺយើងត្រូវខំរួមគ្នាធ្វើយ៉ាងណាដើម្បីឱ្យសង្រ្គាមនេះបាត់សាបសូន្យទៅជាអាតីតកាលដ៏ជូចត់ដែលមិនអាចវិលត្រលប់មកវិញបាន ។ បន្ទាប់មកពីឆ្នាំ ១៩៩៣ ដល់ ១៩៩៩ លោកបានធ្វើជាទីប្រឹក្សានិងជានាយកខុទ្ទកាល័យរបស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** ហើយពេលនោះលោកក៏បានស្គាល់ឯកឧត្តម **ស៊ូ ភិរិន** ជាមិត្តជិតដិតដែរ ។ ដូច្នេះហើយបានជាឯកឧត្តម ស ខេង បានប្រគល់កិច្ចការបោះឆ្នោតនេះឱ្យលោករៀបចំ ហើយលោកក៏បានរៀបចំយ៉ាងសស្រាក់សស្រាំជាមួយនឹងសហគមន៍អន្តរជាតិតាំងពីឆ្នាំ១៩៩៤ ។ គ្រាន់តែ១ឆ្នាំដែលរាជរដ្ឋាភិបាលបានរៀបចំភ្លាម. នៅឆ្នាំ ១៩៩៤ យើងចាប់ផ្តើមគិតគូរអំពីបញ្ហាបោះឆ្នោត ហើយក្នុងរឿងនោះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី មានទស្សនៈវែងឆ្ងាយណាស់ដោយគាត់ថែមទាំងគិតដល់បញ្ហាបោះឆ្នោតឃុំ- សង្កាត់ទៀតនៅជំនាន់នោះដើម្បីធ្វើឱ្យលទ្ធិប្រជាធិបតេយ្យសាយភាយពីលើរហូតដល់ក្រោម និងកុំឱ្យសង្រ្គាមត្រលប់មកវិញបានទៀត ។ ទន្ទឹមនឹងនោះយើងបានរៀនសូត្រពីអ្នកជំនាញជាតិ និងអន្តរជាតិថា តើយន្តការបោះឆ្នោតនៅប្រទេសកម្ពុជាគួរតែរៀបចំដោយរបៀបណា ហើយយើងក៏បានរៀបចំបានមែននៅឆ្នាំ១៩៩៨ ទោះបីជាមានគ្រោះថ្នាក់

នាំឱ្យមានការផ្ទុះអាវុធនៅឆ្នាំ ១៩៩៧ ក៏ដោយ ក៏រាជរដ្ឋាភិបាលជំនាន់នោះនៅតែជំនះរៀបចំការបោះឆ្នោតឱ្យបាន ។ ក្រោយមកពីឆ្នាំ ១៩៩៩រហូតដល់ឆ្នាំ ២០០៣ លោក បានមកធ្វើការជាអ្នកសំរបសំរួលនៃកម្មវិធីដើម្បីសន្តិភាព និងអភិវឌ្ឍន៍របស់ វិទ្យាស្ថាន CDRI ដោយលោកធ្លាប់មាន បទពិសោធន៍ពីរាជរដ្ឋាភិបាលមក លោកគិតថា គួរតែបង្កើតយន្តការមួយដែលយើងអាច នឹងជជែកពិភាក្សាត្រង់ទៅត្រង់មក និងដោយទុកចិត្តគ្នាអំពីបញ្ហាបោះឆ្នោត ។ នៅ CDRI យើងបានធ្វើការស្រាវជ្រាវមួយថាតើ ហេតុអ្វីបានជានៅឆ្នាំ ១៩៩៨ នៅពេលដែលយើងរៀបចំការបោះឆ្នោតនោះមានអំពើហិង្សាច្រើនម្ល៉េះរហូតទៅដល់មតិសាធារណៈ អន្តរជាតិបានឃើញតាមរយះ CNN ។ នៅជំនាន់នោះមានអំពើហិង្សាជាច្រើនដែលព្រះសង្ឃត្រូវបានទទួលរងគ្រោះនៅលើរាងកាយ នេះជាកត្តាធ្វើឱ្យខ្មែរបាត់បង់មោទនៈភាពម្តងទៀតហើយ ។ ដោយសារការស្រាវជ្រាវនោះនាំឱ្យ លោក គិតថា គួរតែបង្កើតយន្តការ មួយដែលជាយន្តការបង្ការទំនាស់មុននឹងទំនាស់កើតឡើងជាវិជ្ជមាន ហើយនៅថ្ងៃទី ២៦ ខែសីហា ឆ្នាំ ១៩៩៩ ជាថ្ងៃដែលយន្តការខប់សែល បានកើតឡើងជាលើកដំបូងបង្អស់ដោយមានការគាំទ្រអំពីព្រះមហាក្សត្រ សម្តេចនាយករដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ដែលមាន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង គាំទ្រយ៉ាងពេញទំហឹងតែម្តង ឯកឧត្តម អ៊ឹម សួស្តី នៅជំនាន់នោះ លោក ជាអគ្គលេខាធិការ គ.ជ.ប លោក តា ចេងផុន ដែលជាគ្រូរបស់លោក គណបក្សនយោបាយធំៗ ព្រមទាំងអង្គការសង្គមស៊ីវិលនានាបានចូលរួមប្រជុំ ជុំរុញឱ្យយន្តការនេះដែលជាយន្តការខ្មែរសុទ្ធសាធបានក្លាយជាវិជ្ជមាន ។វិទ្យាស្ថាន CDRI បានរៀបចំ ៥០ដង ចំពោះ ខប់សែល ដំណាក់កាលទី១ គឺពីខែសីហាឆ្នាំ ១៩៩៩ រហូតទៅដល់ខែកញ្ញាឆ្នាំ ២០០៣ នៅពេលដែលយើង ធ្វើការបោះឆ្នោតចប់ហើយ នៅពេលនោះយន្តការ ខប់សែលក៏ត្រូវបានចាប់ផ្តើមទទួលស្គាល់ខ្លះៗ ហើយដោយមានប្រទេសមួយចំនួន ដូចជា Afganistane និង East timor បានជួបជាមួយលោក ហើយបានសូមឱ្យលោកធ្វើការពន្យល់ថា តើធ្វើយ៉ាងម៉េចទើបនាំឱ្យមាន យន្តការនេះកើតឡើង ។ ក្រោយមកនៅឆ្នាំ២០០៥ លោក Douglas Gardner ជាប្រធានអង្គការ UNDP សព្វថ្ងៃក៏បានជួបជាមួយ លោក ឡារី ស្ត្រេន្ទ និងរូបលោកផ្ទាល់ដើម្បីសូមឱ្យវិទ្យាស្ថាន CDRI រៀបចំយន្តការខប់សែលដំណាក់កាលទី ២ សារជាថ្មីម្តងទៀត ព្រោះយន្តការខប់សែល នេះមានផលប្រយោជន៍ណាស់ក្នុងការបំរើការបោះឆ្នោតសំរាប់ឆ្នាំ ២០០៧ និង ២០០៨ ។ នៅពេលនោះលោកក៏ ធ្វើការ ពិចារណាស៊ីជំរៅ ជាមួយនឹងព្រះសង្ឃគ្រូចៅអធិការជាច្រើនវត្ត និងជួបជាមួយតួអង្គទាំងអស់មាន គណបក្សនយោបាយ រាជរដ្ឋាភិបាល សង្គមស៊ីវិល បានគិតថា យន្តការខប់សែល ដំណាក់កាលទី១ ធ្វើនៅថ្នាក់ជាតិបានជោគជ័យហើយ ប៉ុន្តែទំនាស់ប្រសិនបើយើង អាចបង្ការបាននៅថ្នាក់មូលដ្ឋានជាពិសេសថ្នាក់ឃុំ ថ្នាក់ស្រុក ថ្នាក់ខេត្ត នោះវប្បធម៌នៃការជជែកពិភាក្សាគ្នាក្នុងការបង្ការទំនាស់ នឹងរិតតែមានប្រសិទ្ធិភាពទៀត ។ ដូច្នេះបានជានៅដំណាក់កាលទី ២ ខប់សែល បានធ្វើរឿងថ្មីមួយដែលយើងមិនធ្លាប់ធ្វើហៅថា ខប់សែលប្រ៉ម COPCELPROM ជាការទាញយន្តការពីថ្នាក់ជាតិមកធ្វើនៅថ្នាក់ខេត្តគ្រប់ទាំង ២៤ខេត្ត-ក្រុង ហើយក្នុង១ខេត្ត ពីរដង ដែលម្តងសំរាប់បំរើការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ និងម្តងទៀតសំរាប់បំរើការបោះឆ្នោតថ្នាក់ជាតិនៅឆ្នាំ ២០០៨ នេះ ។ ក្នុងនេះរាជរដ្ឋាភិបាលបានជួយគាំទ្រយ៉ាងខ្លាំងម្តងទៀត ដូច្នេះហើយបានជាលោកសូមឆ្លៀតឱកាសនេះថ្លែងអំណរគុណដល់ ឯកឧត្តម ស៊ូ ភិរិន និងឯកឧត្តមអភិបាលខេត្តឯទៀតៗដែលអនុញ្ញាតិឱ្យខាង លោក រៀបចំការប្រជុំនេះឡើង និងទទួលការស្វាគមន៍យ៉ាងកក់ក្តៅ ។ ខេត្តនេះជាខេត្ត ទី២១ ដែលយើងបានរៀបចំកិច្ចប្រជុំនេះឡើង ហើយស្អែក ខប់សែល នឹងធ្វើនៅខេត្តឧត្តរមានជ័យ និងនៅចុងក្រោយ បំផុតខប់សែលនឹងធ្វើនៅខេត្តព្រះវិហារ និងខេត្តកំពង់ធំ ។ បន្ទាប់មកយើង នឹងធ្វើជុំ ទី ២ សារថ្មីម្តងទៀត ហេតុដូចនេះយន្តការ ខប់សែល ជាពិសេស ខប់សែលប្រ៉ម មានគោលដៅធំៗ៣ គឺ:

ទី១ ការចុះឈ្មោះបោះឆ្នោតៈ ខប់សែល ចង់ធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋខ្មែរមានទំលាប់ជាស្វ័យប្រវត្តិដូចប្រទេសជឿនលឿនឯទៀត១ នៅពេលដែលធំឡើងដល់អាយុ ១៨ឆ្នាំ ដើរទៅចុះឈ្មោះខ្លួនឯងតែម្តងនៅក្រុមប្រឹក្សាឃុំសង្កាត់ ហើយឱ្យលែងមានការចុះឈ្មោះខុស ដូរឈ្មោះចុះឡើង បញ្ហារូបថត និងបញ្ហាដ៏ទៃ១ទៀត ។

ទី២ ដោយសារតែច្បាប់បោះឆ្នោតលើកនេះបានចែងថា មានតែអត្តសញ្ញាណប័ណ្ណទើបអាចបោះឆ្នោតបាន ដូច្នេះបានជា ខប់សែល បានធ្វើការជាមួយក្រសួងមហាផ្ទៃដើម្បីសូមធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋខ្មែរដែលមានអាយុ ១៨ឆ្នាំ បានទទួលអត្តសញ្ញាណប័ណ្ណគ្រប់១គ្នា និងបានទទួលដោយរាជរដ្ឋាភិបាលប្រកាសជាសាធារណៈកុំឱ្យមានអស់លុយអស់កាក់ ដូច្នេះហើយបានជាឯកឧត្តម **ស ខេង** លោក បើកយុទ្ធនាការឆ្នាំ ២០០៦ ជាយុទ្ធនាការគំហុកមួយ គឺក្នុង១ឆ្នាំធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋដែលមិនទាន់បានទទួលអត្តសញ្ញាណប័ណ្ណ ១លាន៩សែន នាក់សូមឱ្យបានទទួលទាំងអស់គ្នា ។ តាម ខប់សែល ដឹងលទ្ធផលទោះមិនបាន ១០០% ក៏ ៩៥% នៃប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសដែលមានអាយុចាប់ពី ១៨ឆ្នាំ ឡើង គឺបានទទួលអត្តសញ្ញាណប័ណ្ណគ្រប់គ្នា ហើយយើងគិតថា ក្នុងតែមួយឆ្នាំ ២០០៧ នេះទៀត នឹងធ្វើយ៉ាងណារួមគ្នាជាមួយ និង NEC វិទ្យាស្ថាន CDRI និងក្រសួងមហាផ្ទៃ ដើម្បីឱ្យ ប្រជាពលរដ្ឋខ្មែរមានអត្តសញ្ញាណ ប័ណ្ណគ្រប់១គ្នាតែម្តង ។ បន្ទាប់មកយើង នឹងធ្វើការអប់រំដល់ប្រជាពលរដ្ឋរបស់យើងសូមអង្វរ លោក ឱ្យឈប់ដូរឈ្មោះទៅព្រោះដល់ពេលទៅធ្វើអត្តសញ្ញាណប័ណ្ណដាក់ឈ្មោះផ្សេងនាំឱ្យអាជ្ញាធរខេត្ត, ស្រុក វង្វេងវង្វាន់អស់ហើយ សូមឱ្យយើងមានការប្រយ័ត្ននូវអក្ខរាវិរុធឈ្មោះរបស់យើង ព្រោះកន្លងមកយើងមិនសូវយកចិត្តទុកដាក់ទេចំពោះបញ្ហាហ្នឹង ។ ដូច្នេះ ខប់សែល សង្ឃឹមថាប៉ុន្មានឆ្នាំទៅមុខទៀតបញ្ហាអត្តសញ្ញាណប័ណ្ណលែងចោទជាបញ្ហាទៀតនៅក្នុងប្រទេសកម្ពុជាយើង ព្រោះនៅក្នុង ប្រទេសនិមួយ១ពេលយើងកើតជាពលរដ្ឋដល់អាយុ ១៨ឆ្នាំ បញ្ហាអត្តសញ្ញាណប័ណ្ណ គឺជាបញ្ហាមូលដ្ឋានតែម្តង កាលណាគ្មាន អត្តសញ្ញាណប័ណ្ណយើងមិនអាចរៀន, ធ្វើការ, បើកលុយឬធ្វើអ្វីផ្សេង១ទៀតបានទេ គឺវាហាក់ដូចជាយើងគ្មានរូបនៅក្នុងទឹកដីនោះ អញ្ចឹង ដូច្នេះហើយបានជាយើងជំរុញបញ្ហាហ្នឹងសំខាន់ណាស់ដើម្បីឱ្យប្រជាពលរដ្ឋមានអត្តសញ្ញាណប័ណ្ណគ្រប់១គ្នា ។

ទី៣ គឺធ្វើយ៉ាងណាឱ្យយន្តការបោះឆ្នោតនៅប្រទេសកម្ពុជាក្លាយទៅជាយន្តការមួយប្រកបទៅដោយសន្តិភាពដូចដែលអ្នកស្រី **Margie Cook** មានប្រសាសន៍អំបាញ់មិញ ។ លុះមដល់ពេលដែល ពេលបោះឆ្នោតម្តង១ ត្រូវឱ្យការបោះឆ្នោតក្លាយទៅជា យន្តការមួយស្ងប់ស្ងាត់ប្រកបដោយសន្តិភាព គឺឈ្នះដោយមានកិត្តិយស ហើយចាញ់ដោយអស់ចិត្តមានន័យថា អ្នកចាញ់ក៏ទទួលចាញ់ ហើយអ្នកឈ្នះក៏ឈ្នះដោយគ្មានការក្រអឺតក្រទម គ្មានការវាយឬក ។ ឈ្នះដោយប្រជាពលរដ្ឋប្រគល់សន្លឹកឆ្នោតជូនឱ្យដឹកនាំប្រទេសជាតិមិនមែនឈ្នះនៅលើការបង្ខិតបង្ខំ ការបំភ័យឬមួយក៏អំពើហិង្សានោះទេ ។ នេះជាគោលដៅធំទី ៣ របស់ ខប់សែល ដែលយើងសង្ឃឹមថា ប្រសិនបើប្រទេសកម្ពុជាធ្វើដូច្នេះបានការអភិវឌ្ឍន៏ការជឿទុកចិត្តពីសហគមន៍អន្តរជាតិ ពីអ្នកវិនិយោគ នឹងមកហូរហែរដូចយើងទើបបញ្ចប់ពិពណ៌អន្តរជាតិប៉ុន្មានថ្ងៃនេះ គឺធ្វើឱ្យសៀមរាបមានមតិសាធារណៈស្គាល់ច្រើនណាស់ ដូច្នេះការកសាងរបស់យើងទំរាំបានមកដូចថ្ងៃនេះ គឺយើងពិបាកណាស់ក្នុងរយៈពេលជាង១០ឆ្នាំកន្លងមកនេះ ប៉ុន្តែប្រសិនបើយើងមិនស្តាប់គ្នាវិញនោះការកសាងដែលលំបាកយ៉ាងខ្លាំងនេះ នឹងរលាយទៅវិញយ៉ាងឆាប់ខ្លាំងណាស់ឱ្យតែមានការឈ្លោះប្រកែកគ្នា ។ ដូចនេះហើយបាន ជាយើងចង់ធ្វើយ៉ាងណាឱ្យយន្តការនៃការបោះឆ្នោតនៅប្រទេសកម្ពុជាបានទទួលនូវសន្តិសុខ ។ ទាំងអស់នេះ គឺជាគោលដៅរបស់ យន្តការ ខប់សែល ហើយខប់សែល សង្ឃឹមថា នៅពេលដែល ខប់សែល ទី២ ចប់ វប្បធម៌នៃការជជែកពិភាក្សាគ្នាដើម្បីបង្ការទំនាស់ និងដោះ ស្រាយទំនាស់នៅក្នុងឥរិយាបថថ្លៃថ្នូរ និងជាកិត្តិយសរបស់ប្រទេសជាតិ នេះហើយដែលអ្នករៀបចំយន្តការខប់សែល ទាំងដំណាក់ កាលទី១

និងទី២ ចង់បាន ដើម្បីឱ្យប្រទេសជាតិរបស់យើងមានអ្វីជំរាបប្រាប់ទៅមតិជាតិ និងអន្តរជាតិថា យើងមិនមែនតែល្បីរឿងសង្គ្រាមកាប់សំលាប់គ្នាទេ គឺយើងល្បីទាំងរឿងល្អផ្ទួនផង សន្តិភាព និងការជជែកពិភាក្សាគ្នាក្នុងភាពថ្លៃថ្នូរនិងកិត្តិយស ។

### ០៣.ស្ថានភាពទូទៅនៃការបោះឆ្នោតថ្លែងដោយ លោក នឹម វ៉ាន់សំ ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោត ខេត្តសៀមរាប

ក្នុងនាមគណៈកម្មការខេត្តរៀបចំការបោះឆ្នោតខេត្តសៀមរាប លោក មានសេចក្តីរីករាយដែលបានចូលរួមកម្មវិធី ខប់សែលប្រ៉មដំណាក់កាល ទី២ លោកសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមជ្ឈមណ្ឌលដើម្បីសន្តិភាព និងអភិវឌ្ឍន៍នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាដែលបានរៀបចំអង្គពិធីនេះ ប្រកបទៅដោយអត្ថន័យខ្លឹមសារ និងស្របពេលជាមួយនឹងដំណើរការនៃរៀបចំការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី ២ ឆ្នាំ២០០៧ នេះផងដែរ ។ លោក សូមកោតសរសើរចំពោះយន្តការខប់សែល ដែលបានខិតខំស្វែងរកការគាំទ្រ និងបានបំពេញតួនាទីដ៏ឧត្តុង្គឧត្តមក្នុងការស្វែងរកគ្រប់មធ្យោបាយប្រយោជន៍បង្ការទប់ស្កាត់នូវទំនាស់នានាក្នុងដំណើរការនៃការបោះឆ្នោត ។ ជាទូទៅដំណើរការនៃការរៀបចំការបោះឆ្នោតតែងតែមានទំនាស់ពោល គឺការចាប់ពីដំណាក់កាលដំបូងរហូតដល់ប្រកាសលទ្ធផល កន្លងមក ខប់សែល បានបំពេញតួនាទីយ៉ាងសកម្មក្នុងការបង្ការនិងរកដំណោះស្រាយទំនាស់ព្រមទាំងបង្កើនជំនឿទុកចិត្តពីគ្រប់មជ្ឈដ្ឋានទាំងអស់ ។ លោក សង្ឃឹមជឿជាក់ថា វិទ្យាស្ថាន CDRI តាមរយៈ ខប់សែល នឹងបន្តប្រព្រឹត្តិសមធម៌ និងតម្លាភាពសំរាប់ដំណើរការនៃការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី ២ នេះបន្តទៅទៀតសំដៅកាត់បន្ថយនូវទំនាស់នានា និងវិធីសាស្ត្រដោះស្រាយទំនាស់ប្រកបដោយសន្តិវិធីព្រមទាំងឱ្យទទួលបានលទ្ធផលសម្រុះសម្រួល ពីគ្រប់គណបក្សនយោបាយទាំងអស់ ជាមួយគ្នានេះដែរ លោក ក៏សូមថ្លែងអំណរគុណចំពោះគណៈចាត់តាំងកម្មវិធីដែលបានផ្តល់កិត្តិយសឱ្យ លោក ឡើងធ្វើបទអន្តរាគមន៍ពាក់ព័ន្ធ នឹងការបោះឆ្នោតនេះ ។ ខាងក្រោមនេះជាលទ្ធផលដែលគណៈកម្មការរៀបចំការបោះឆ្នោតខេត្តសៀមរាបសំរេចបានកន្លង មកៈ

**I.ការអនុវត្តការងារកន្លងមក**

អង្គប្រជុំទាំមូលបានជ្រាបហើយថា ខេត្តសៀមរាបមាន ១២ស្រុក ១០០ឃុំ និង ៨៧៥ភូមិ ការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី១ មានការិយាល័យ ចំនួន ៧៣២ការិយាល័យ ក្រោយបច្ចុប្បន្នភាពបញ្ជីឈ្មោះឆ្នាំ២០០៦ មានការិយាល័យរហូតដល់ ៨១៨ការិយាល័យ បើប្រៀបនឹងអាណត្តិ ទី១ មានការកើនឡើងចំនួន ៨៦ការិយាល័យ ។ ដើម្បីរៀបចំដំណើរការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី២ ខាងមុខនេះ ប្រកបទៅដោយប្រសិទ្ធិភាពនិងយោងតាមសេចក្តីណែនាំរបស់ គ.ជ.ប. គណៈកម្មាខេត្តរៀបចំការបោះឆ្នោតខេត្តសៀមរាប បានជ្រើសរើសគណៈកម្មាការឃុំរៀបចំការបោះឆ្នោត ទាំង១០០ឃុំ ដែលមានមន្ត្រីចំណុះឱ្យគណៈកម្មាចំនួន៥០០នាក់។

ទី១ ការចុះឈ្មោះបោះឆ្នោតៈ លោក បានបង្កើតនិងបែងចែកក្រុមអ្នកផ្តល់ប័ណ្ណពត៌មានដល់អ្នកបោះឆ្នោតមុនពេលចុះឈ្មោះបោះឆ្នោត តាមបណ្តាភូមិ ឃុំ ស្រុកទាំង១២ ទូទាំងខេត្តសៀមរាប និងបានបិទផ្សាយការិយាល័យចុះឈ្មោះបោះឆ្នោត និងចំនួនការិយាល័យបោះឆ្នោត ។ បញ្ជីឈ្មោះអ្នកបោះឆ្នោតនៅឆ្នាំ២០០៥ មាន៣ ៦៥៩២៥នាក់ ក្នុងនោះធ្វើបច្ចុប្បន្នភាពសំរាប់ឆ្នាំនេះបានទិន្នន័យដូចតទៅៈ អ្នកចុះឈ្មោះថ្មីបានចំនួន ៦៥៦០២នាក់ លើផែនការ ៥៣៤៩៩នាក់ លុបឈ្មោះចេញពីបញ្ជីមានចំនួន ១០២៧៦នាក់ ហើយចំនួនអ្នកបោះឆ្នោតដែលនៅសល់ គឺ ៤២១២៥៥នាក់ ។ ដំណាក់កាលនៃការចុះឈ្មោះនេះខាង លោក មានការខ្វះខាតនូវទំរង់ ១០១៨ ដោយសារការផ្តល់ពីគ.ជ.ប មានការយឺតយ៉ាវ ប៉ុន្តែត្រូវបានគណបក្សនយោបាយទាំង ៣ ជួយឧបត្ថម្ភ រឺឯរូបថតវិញតំណាងគណបក្ស

នយោបាយមួយចំនួនបានចុះទៅថតឱ្យប្រជាពលរដ្ឋដល់សាលាឃុំតែម្តងចំពោះបញ្ហានេះ លោក គិតថា វាអាចសល់តិចតួច ។ ក្នុងដំណើរការចុះឈ្មោះបោះឆ្នោតខាងលោកទទួលបានបណ្តឹងពីរ បណ្តឹងទី១ គឺធ្វើការដោះស្រាយនៅថ្នាក់ឃុំដោយក្រុមប្រឹក្សាឃុំ-សង្កាត់នៅឃុំចុងឃ្នៀសសំរេចលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតចំនួន ២២នាក់ ចំណែកឯបណ្តឹងមួយទៀតមានលក្ខណៈដូចគ្នាដែរសុំលុបឈ្មោះជនជាតិវៀតណាម ចេញពីបញ្ជីបោះឆ្នោតនៅឃុំចុងឃ្នៀសដដែល ចំពោះករណីនេះខាង លោក បានបញ្ជូនទៅដល់ គ.ជ.ប ហើយគ.ជ.បបានបន្តទៅដល់រដ្ឋធម្មនុញ្ញ ។ ក្រោយពីបានពិនិត្យ ក្រុមប្រឹក្សាធម្មនុញ្ញបានសំរេចលុបឈ្មោះចំនួន ២៨នាក់ ទៀតចេញពីបញ្ជីអ្នកបោះឆ្នោត សរុបមក PEC លុបឈ្មោះបានចំនួន ៥០នាក់ ចេញពីបញ្ជីអ្នកបោះឆ្នោត ។

ទី២ អំពីការប្រជុំផ្សព្វផ្សាយៈ គណកម្មាការខេត្តរៀបចំការបោះឆ្នោតបានបើកការប្រជុំ និងរៀនសូត្រការងារដែលពាក់ពន្ធ័ និងដំណើរការនៃការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី ២ ឆ្នាំ ២០០៧ ដោយមានការចូលរួមពីគ្រប់តំណាងគណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល ព្រមទាំងបានផ្តល់នូវឯកសារ លិខិតបទដ្ឋាននានាដែលពាក់ពន្ធ័ នឹងការបោះឆ្នោតដល់គណបក្សនយោបាយ ស្ថាប័នអង្គភាពអាជ្ញាធរ អង្គការសង្គមស៊ីវិលនានាក្នុងខេត្ត ។ បើកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីណែនាំ ០១០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីអំពីការផ្តល់ប័ណ្ណព័ត៌មានរបស់ក្រសួងមហាផ្ទៃ និង គ.ជ.ប កាលពីថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៧ ដោយមានការចូលរួមពីឯកឧត្តម អភិបាលខេត្ត អភិបាលស្រុក មេឃុំ ជំទប់ឃុំ និងមន្ត្រីគណកម្មាការឃុំរៀបចំការបោះឆ្នោតទូទាំងខេត្តបានចែកខិតប័ណ្ណ បែងចែកប័ណ្ណព័ត៌មានដល់គ្រប់ភូមិដើម្បីផ្សព្វផ្សាយ និងឱ្យទំនាក់ទំនងទៅមន្ទីរព័ត៌មានដើម្បីធ្វើអន្តរាគមន៍ទៅវិទ្យុ និងទូរទស្សន៍ក្នុងខេត្តក្នុងគោលបំណងជូនដំណឹងដល់ប្រជាពលរដ្ឋឱ្យទៅយកប័ណ្ណពតិមានតាមបណ្តាលភូមិឃុំដែលបងប្អូនកំពុងរស់នៅ ។

## II. ការងារអ្នកសង្កេតការជាតិ និងអន្តរជាតិ

### ១.អង្គការក្រៅរដ្ឋាភិបាល

អង្គការជាតិ និងអន្តរជាតិ ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី ២ គិតមកដល់ថ្ងៃនេះមានចំនួន ១៤២នាក់ ក្នុងនោះស្ត្រីមាន ៤៣នាក់ ដោយមានអង្គការនិងសមាគមន៍ដូចជាៈ អង្គការខុមហ្វ្រែលមានចំនួន ៤៦នាក់ ក្នុងនោះស្ត្រី ៧នាក់ អង្គការនិចហ្វិចមានចំនួន ២នាក់ ក្នុងនោះស្ត្រី ០នាក់ អង្គការស្ត្រីកម្ពុជាដើម្បីអភិវឌ្ឍន៍មានចំនួន ៦នាក់ ក្នុងនោះស្ត្រី ២នាក់ អង្គការសម្ពន្ធ័ស្ត្រីខ្មែរការពារសិទ្ធិមនុស្សមានចំនួន ០៥នាក់ ក្នុងនោះស្ត្រី ៣នាក់ អង្គការលើកស្ទួយសុខមាលភាពជនក្រីក្រមានចំនួន ៥នាក់ ក្នុងនោះស្ត្រី ២នាក់ អង្គការសង្រ្គោះអនាគតកុមារខ្មែរចំនួន ១នាក់ ក្នុងនោះស្ត្រី ០១នាក់ អង្គការអភិវឌ្ឍន៍ជនបទចំនួន ៤នាក់ ក្នុងនោះស្ត្រី ៣នាក់ អង្គការអភិវឌ្ឍន៍តំបន់ព្រំដែនមានចំនួន ០៧នាក់ ស្ត្រី ១នាក់ សមាគមន៍ស្ត្រីមេម៉ាយអភិវឌ្ឍន៍កម្ពុជាមានចំនួន ០៧នាក់ ស្ត្រី ១នាក់ សមាគមន៍ YCC មានចំនួន ៥២នាក់ ស្ត្រី ១៩នាក់ សមាគមន៍សំរាប់អភិវឌ្ឍន៍សិទ្ធិមនុស្សមានចំនួន ០៤នាក់ ស្ត្រី ០២នាក់ សមាគមន៍មូលលិធិអភិវឌ្ឍន៍តាមជាយដែនចំនួន ៦នាក់ ក្នុងនោះស្ត្រី ២នាក់ ។

### ២ គណបក្សនយោបាយ

ចំពោះអ្នកសង្កេតការណ៏មកពីតំណាងគ្រប់គណបក្សនយោបាយចំនួនសរុប ៥៦០៩នាក់ ក្នុងនោះស្ត្រី ១១៩៥នាក់ គណបក្សនយោបាយដែលចូលរួមសង្កេតការណ៏មាន គណបក្ស ប្រជាជន ចំនួន ១៦២៩នាក់ ក្នុងនោះស្ត្រី ១៧៥នាក់ គណបក្ស ហ៊្វុនស៊ិនប៉ិច សរុបចំនួន ១៤៣៨នាក់ ក្នុងនោះស្ត្រី ៣៥៦នាក់ គណបក្ស សមរង្ស៊ី សរុបចំនួន ១៥៤៤នាក់ ក្នុងនោះស្ត្រី ៣២៨នាក់ គណបក្ស នរោត្តមរណឬទ្ធិ សរុប ៩៨២នាក់ ក្នុងនោះស្ត្រី ២៩៤នាក់ គណបក្សរណសិរ្សសង្គមជាតិនិយមសរុប ១១នាក់ ក្នុងនោះស្ត្រី ០នាក់ គណបក្សប្រជាធិបតេយ្យខ្មែរសរុប ០៥នាក់ ក្នុងនោះស្ត្រី ២នាក់ ។

**III.ការចុះបញ្ជីគណបក្សនយោបាយ**

អណត្តិទី ២ នៃការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ គណបក្សនយោបាយចំនួន ៦ ដែលបានចូលរួម និងឈរឈ្មោះក្នុងទូទាំង ១០០ឃុំ នៅខេត្តសៀមរាប ។ ចំពោះការចុះឈ្មោះបញ្ជីបេក្ខជនគណបក្សនយោបាយ សំរាប់ការបោះឆ្នោតក្រុមប្រឹក្សាក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី២ ឆ្នាំ២០០៧ ។ គណកម្មាកាខេត្តរៀបចំការបោះឆ្នោតបានទទួលឈ្មោះ និងអ្នកឈរឈ្មោះបោះឆ្នោតទាំង ១០០ឃុំ របស់គណបក្សនយោបាយដូចតទៅៈ គណបក្សប្រជាជនដាក់ពាក្យបាន ១០០ឃុំ ចំនួនអ្នកឈរឈ្មោះបោះឆ្នោតបាន ១៩៣៨នាក់ ក្នុងនោះស្ត្រី ២៩០នាក់ ។ គណបក្ស ហ៊្វុន ស៊ិនប៉ិច ដាក់ពាក្យបាន ១០០ឃុំ ចំនួនអ្នកឈរឈ្មោះបោះឆ្នោតសរុបបានចំនួន ១៤០២នាក់ ក្នុងនោះស្ត្រី ២១៩នាក់ គណបក្ស សមរង្ស៊ី ដាក់បាន ៩៩ឃុំ អវត្តមាន ១ឃុំ នៅឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង ចំនួនអ្នកឈរឆ្នោះបោះឆ្នោតសរុបចំនួន ១៣៩៥នាក់ ស្ត្រី ២៣០នាក់ ។ គណបក្ស នរោត្តម រណប្ញទ្ធី ដាក់ពាក្យបាន ៨១ឃុំ អ្នកឈរឈ្មោះសរុបមានចំនួន ១២០៨នាក់ ក្នុងនោះស្ត្រី ៣៩២នាក់ ។ គណបក្សរណសិរ្សសង្គមជាតិនិយមដាក់ពាក្យបាន៣ឃុំ អ្នកឈរឈ្មោះបោះឆ្នោតសរុប ៤៦នាក់ ក្នុងនោះស្ត្រី ២៦នាក់ គណបក្សប្រជាធិបតេយ្យខ្មែរដាក់ពាក្យបាន ១ឃុំ គឺឃុំចាន់ស ស្រុកសូទ្រនិគម ចំនួនអ្នកឈរឈ្មោះសរុប ១៤នាក់ ក្នុងនោះស្ត្រី ៦នាក់ ។ ការងាររៀបចំចាប់ចំណាប់លេខរៀងគណបក្សនយោបាយ គឺអនុវត្ត ២ថ្ងៃ នៅថ្ងៃ ២០ ខែ មករា ឆ្នាំ ២០០៧ ចាប់ចំណាប់លេខរៀងបានចំនួន ៥៥ឃុំ និងថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៧ ចាប់ចំណាប់លេខរៀងបានចំនួន ៤៥ឃុំ ដូច្នេះទូទាំងខេត្តយើងបញ្ចប់ការចាប់នៅថ្ងៃទី ២១ ក្នុងនោះគណបក្សនយោបាយដែលបានទទួលលំដាប់លេខរៀងមានដូចខាងក្រោមៈ គណបក្សប្រជាជនបានលំដាប់លេខរៀង ទី១ ចំនួន ២៤ឃុំ លំដាប់លេខរៀងទី២ ចំនួន ២២ឃុំ លេខរៀងទី ៣ ចំនួន ២៩ឃុំ លំដាប់លេខរៀងទី ៤ ចំនួន ២៥ឃុំ, គណបក្ស ហ៊្វុនស៊ិនប៉ិច បានលំដាប់ទី ១ ២៦ឃុំ លំដាប់ទី ២ ចំនួន ២៦ឃុំ លំដាប់លេខ ៣ ចំនួន ២៥ឃុំ លំដាប់លេខ៤ ចំនួន ២២ឃុំ លំដាប់លេខ៥ ចំនួន ១ឃុំ ។ គណបក្ស សមរង្ស៊ី លំដាប់លេខ១ ចំនួន ៣៥ ឃុំ លំដាប់លេខ២ ចំនួន ២៣ ឃុំលំដាប់លេខ៣ ចំនួន ២៧ឃុំ លំដាប់លេខ៤ ចំនួន ១៤ឃុំ ។ គណបក្ស នរោត្តម រណប្ញទ្ធី លំដាប់លេខ១ ចំនួន ១៥ឃុំ លំដាប់លេខ២ ចំនួន ២៨ឃុំ លំដាប់លេខ៣ ចំនួន ១៧ឃុំ លំដាប់លេខ៤ ចំនួន ១៩ឃុំ លំដាប់លេខ៥ ចំនួន ២ឃុំ ។ គណបក្សរណសិរ្ស សង្គមជាតិនិយមលំដាប់លេខ១ ចំនួន ០ លំដាប់លេខ២ ចំនួន ០ លំដាប់លេខ៣ ចំនួន ១ឃុំ លំដាប់លេខ៤ ចំនួន ១ឃុំ លំដាប់លេខ៥ ចំនួន ១ឃុំ ។ គណបក្ស ប្រជាធិបតេយ្យខ្មែរ លំដាប់លេខ១ ចំនួន ០ លំដាប់លេខ២ ចំនួន ១ឃុំ លំដាប់លេខ៣ លេខ៤ និងលំដាប់លេខ៥ ចំនួន ០ ។

**IV.ផែនការណ៍អនុវត្តបន្ត**

គណកម្មាការខេត្តរៀបចំការបោះឆ្នោត នឹងបន្តអនុវត្តនូវផែនការណ៍សំខាន់ៗ ដូចខាងក្រោមៈ

១. ការជ្រើសរើសមន្ត្រីការិយាល័យចំនួន ៤៩០៨នាក់ សំរាប់ការិយាល័យទាំង ៨១៨ការិយាល័យ ទូទាំងខេត្តសៀមរាប ជំនួយ និងពង្រឹងកងកំលាំងចែកប័ណ្ណព័តិអ្នកបោះឆ្នោត បន្តចែកប័ណ្ណអ្នកបោះឆ្នោតលើក ទី២ ចុះត្រួតពិនិត្យជាប្រចាំអំពីសកម្មភាពការងាររបស់ គ.ឃ.ប និងគ្រប់ការិយាល័យទាំងអស់ទូទាំងខេត្ត សហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ដើម្បីពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនាពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត ការដឹកជញ្ជូនសំភារៈ បរិក្ខារនានា ចរាចរចល័តរវាងការិយាល័យបោះឆ្នោត គ.ឃ.ប, គ.ខ.ប និង គ.ជ.ប ។

២. ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតៈ តាំងនាមគណកម្មាការខេត្តរៀបចំការបោះឆ្នោត លោក សូមវាយតំលៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការរបស់អជ្ញាធរដែនដី អង្គការសង្គមស៊ីវិល ដែលបានយកចិត្តទុកដាក់យ៉ាងសកម្មក្នុងដំណើរការបោះឆ្នោត

កន្លងមក ចំពោះមុខ លោក សង្ឃឹមថា ឯកឧត្តម អស់លោក លោកស្រី តំណាងអជ្ញាធរដែនដី សមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ តំណាងអង្គការសង្គមស៊ីវិល និងបន្តប្រពៃណីសហការដ៏ល្អនេះជាបន្តទៅទៀតដើម្បីត្រៀមលក្ខណៈចូលរួម នៅក្នុងដំណើរការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី២ខាងមុខនេះសំរេចបានលទ្ធផលល្អប្រសើរ ។

ជាទីបញ្ចប់ លោក សូមប្រសិទ្ធីពរបវរប្រសើរជូនចំពោះអង្គប្រជុំទាំងមូលសូមប្រកបបាននូវពុទ្ធពរទាំង ៥ប្រការ គឺអាយុ វណ្ណះ សុខៈ ពលៈ និងបដិភនៈ កុំបីឃ្លៀវឃ្លាតឡើយ ។

## ០៤.មតិរបស់អ្នកចូលរួមដែលបង្ហាញអំពីការប្រឈមនានាំងឡាយ ក្នុងយន្តការរៀបចំការបោះឆ្នោតក្នុងបរិបទ ខេត្តសៀមរាប

លោក **បាន សម្ភីរ** សមាជិកក្រុមប្រឹក្សាឃុំមកពីគណបក្ស សម រង្ស៊ី មានចំណាប់អារម្មណ៍ថា ឆ្លងតាមរយៈការបោះឆ្នោតជាច្រើនលើកកន្លងមកឃើញថា អំពើហិង្សដែលកើតមាននាពេលបោះឆ្នោតម្តងៗ មានការថយចុះជាអតិបរិមានេះ ដោយសារតែការខិតខំប្រឹងប្រែងរបស់ រាជរដ្ឋាភិបាលនិងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ទាំងអស់ដែលបានយកចិត្តទុកដាក់និងខិតខំប្រឹងប្រែងចង់ជួយខ្លួនឯងផង និងចង់បង្ហាញឱ្យអន្តរជាតិមើលឃើញថា កម្ពុជាពិតជាមានចេតនាចង់ជួយខ្លួនឯង ពិតប្រាកដមែន ប៉ុន្តែទោះបីជាយើងទាំងអស់គ្នាខិតខំ ប្រឹងប្រែងយ៉ាងណាក៏ដោយ ក៏នៅមានចំណុចអវិជ្ជមានខ្លះៗដែលនៅសេសសល់ហើយចេះតែមកយារយីរយើងមិនចេះឈប់ឈរសោះ ប៉ុន្តែសំរាប់ស្រុកជីក្រែងរបស់ លោក ដែលមានឃុំសរុប ១២ ដោយមានការខិតខំប្រឹងប្រែងរបស់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ធ្វើឱ្យអំពើអសកម្មដែលកើតឡើងនៅពេលបោះឆ្នោតមានការថយចុះជាអតិបរិមារហូតធ្វើឱ្យគណបក្ស សម រង្ស៊ី បានចូល រួមធ្វើការជាមួយគណបក្សនានាបានដល់ទៅ ១១ឃុំ លើ ១២ឃុំ នេះជាចំនុចវិជ្ជមានមួយសំរាប់ស្រុកជីក្រែង ។ ទន្ទឹមនឹងនោះ លោក ក៏បានកត់សំគាល់ឃើញថា យើងពិតជាមានអ្នកដឹកនាំមួយដែលប្រកបទៅដោយមនសិការ និងមានភាពជាអ្នកដឹកនាំពិតប្រាកដ ទើបធ្វើឱ្យគណបក្សប្រឆាំងអាចចូលរួមធ្វើការជាមួយបណ្តាគណបក្សផ្សេងៗបានយ៉ាងល្អប្រសើរ ក៏ប៉ុន្តែទោះបីជាយើងខិតខំប្រឹងប្រែងយ៉ាងនេះក្តីក៏នៅមានចំណុចខ្វះខាតមួយចំនួនបើនិយាយជារួម តែបើនិយាយដោយឡែកក្នុងស្រុកជីក្រែង គឺនៅសល់តិចតួចទេ ។ លោក មានសង្ឃឹមថា ចំណុចអវិជ្ជមានទាំងឡាយដែលនៅសល់តិចនោះ ភាគច្រើនកើតមាននៅតាមភូមិ ។ ហើយប្រសិនបើ លោក លោកស្រី អ្នកនាងកញ្ញា និងអាជ្ញាធរនៅគ្រប់លំដាប់ថ្នាក់ខិតខំប្រឹងប្រែងសម្របសម្រួលធ្វើយ៉ាងណាឱ្យ លោក មេភូមិ ជំនួយការភូមិ និងអនុប្រធានភូមិធ្វើការកុំឱ្យខុសអំពីសៀវភៅដែល គជប បានចែកជូនម្នាក់ៗស្តីអំពីដំណើរការបោះឆ្នោតនោះ លោក ជឿជាក់ថា ប្រជាពលរដ្ឋខ្មែរដែលមានអាយុ ១៨ឆ្នាំឡើង ប្រាកដជាអញ្ជើញទៅបោះឆ្នោតបានគ្រប់ៗគ្នាជាក់ជាមិនខាន ។

លោក **ងួន ណារ៉ា** មកពីតុលាខេត្តសៀមរាបបានមានប្រសាសន៍ថា បើគិតតាំងពីក្រោយមានកិច្ចព្រងព្រៀងក្រុងប៉ារីសរហូតមកដល់ពេលនេះ ប្រទេសកម្ពុជាបានឆ្លងកាត់ការបោះឆ្នោតធំៗជាច្រើនលើកមកហើយដូចជា ការបោះឆ្នោតជ្រើសរើស សមាជិករដ្ឋសភាបានធ្វើ ៣លើក រួចមកហើយ គឺនៅឆ្នាំ ១៩៩៣ ១៩៩៨ និងឆ្នាំ ២០០៣ ។ ម្យ៉ាងទៀតយើងក៏បានរៀបចំការបោះឆ្នោតព្រឹទ្ធសភាបាន ១លើក និងធ្វើការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់បាន ១លើក ដែរ ហើយមិនដល់ ២ខែ ទៀតទេយើងនឹងធ្វើការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ម្តងទៀត ។ ពីដំណាក់កាលមួយទៅដំណាក់កាលមួយអំពើហិង្សាមានការប្រែប្រួលដូចអ្វីដែលលោក តំណាង គណបក្ស សម រង្ស៊ី បានលើកឡើងរួចមកហើយ ។ ចំពោះរូប លោក ផ្ទាល់ លោក យល់ថា ការប្រែប្រួលនេះ គឺដោយសារតែមានការចូលរួមចំណែកពីអង្គការជាតិ អង្គការអន្តរជាតិ និងការខិតខំយកចិត្តទុកដាក់ពីអាជ្ញាធរគ្រប់ជាន់ថ្នាក់ក៏ដូចជាការយកចិត្តទុកដាក់យល់ដឹងពីប្រជាពលរដ្ឋគ្រប់ៗគ្នាដែរ ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏យើងនៅតែពង្រឹងការបង្ការ និងការចូលរួមចំណែកសំដៅជុំរុញ

ឱ្យការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ខាងមុខនេះឱ្យកាន់តែប្រសើរថែមទៀតមិនថាតែប្រទេសយើងនោះទេ ទោះជាប្រទេសជឿនលឿន ឬ ប្រទេសដែលយល់ដឹងលទ្ធិប្រជាធិបតេយ្យគោរពសិទ្ធិសេរីភាពគ្នាយ៉ាងណា ក៏ដោយ ក៏វានៅតែអាចមានអំពើអសកម្មទាក់ទងនឹងការបោះឆ្នោតនេះដែរ ដូច្នេះ លោក សូមឱ្យអ្នកចូលរួមមកពីខាងមូលដ្ឋានផ្ទាល់លើកឱ្យបានច្រើន ហើយអំពើហិង្សានោះអាចចែកចេញជាពីរ ទី១ គឺជាអំពើប៉ះពាល់ដល់ការបោះឆ្នោតហើយអំពើនោះត្រូវដោះស្រាយដោយគណកម្មារៀបចំការបោះឆ្នោតមានគណកម្មាការរៀបចំការបោះឆ្នោតឃុំ-សង្កាត់ ខេត្ត-ក្រុង និងថ្នាក់ជាតិ ប៉ុន្តែអំពើខ្លះទៀតវាមិនមែនជាអំពើដែលត្រូវដោះស្រាយដោយគណកម្មាការរៀបចំការបោះឆ្នោតទេ តែជាអំពើដែលបណ្តាលឱ្យទៅជាអំពើល្មើសព្រហ្មទណ្ឌ ដូចជារឿងវាយដំ ជេរប្រមាថមនុស្សឃាតជាដើម ។ ដោយឡែកទាក់ទង នឹងការងាររបស់ លោក ផ្ទាល់នៅតុលាការរហូតមកទល់ពេលនេះចំពោះសំនុំរឿង ដែលលោក កាន់ទាំងរឿងស៊ីវិលព្រហ្មទណ្ឌ គឺមិនទាន់បានជួបប្រទះនូវទំនាស់ដែលកើតចេញពីមូលហេតុបោះឆ្នោត ឬ នយោបាយ នៅឡើយទេ ហើយ លោក សូមឱ្យអ្នកចូលរួមមកពីខាងមូលដ្ឋានលើកឡើងនូវបញ្ហា ដូច្នេះយើងអាចចូលរួមដោះស្រាយទាំងអស់គ្នា ។

លោក **ឈន គឹមឃន** ក្រុមប្រឹក្សាឃុំ គណបក្សសម រង្ស៊ី ឃុំស្លក្រាម ស្រុកសៀមរាប មានចំងល់ពីរទាក់ទង នឹងការបោះឆ្នោត ទី១ លោកចង់សួរថា តើការចែកបណ្ណ័ពតិមានលើកនេះមានបញ្ហាដូចវគ្គទី១ ដែរឬទេ? ព្រោះការចែកប័ណ្ណព័តិមាននៅវគ្គទី១ មានបញ្ហាខុសឆ្គងខ្លះ ។ នៅក្នុងភូមិ របស់ លោក ដោយសារតែពេលបោះឆ្នោតប្រជាពលរដ្ឋខ្លះទៅបោះនៅការិយាល័យខុស១ គ្នា ជាក់ស្តែងខ្លះរស់នៅ ភូមិទ្រាង ទៅបោះនៅមណ្ឌលបី ឯខ្លះទៀតនៅចុងកៅស៊ូមកបោះនៅមណ្ឌលបីក៏មាន ។ ហើយពេលចែកប័ណ្ណព័តិមាន មេភូមិខ្លះរកមិនឃើញប្រជាពលរដ្ឋនៅភូមិរបស់ខ្លួន ក៏លុបឈ្មោះគេចេញ ។ ពេលសង្កេតការណ៍ លោក បានរើសមនុស្ស ៥០នាក់ ចូលសង្កេតការណ៍ បោះឆ្នោតស្រាប់តែបាត់ឈ្មោះអស់ ៣០% មេភូមិថា មានអ្នកខ្លះផ្លាស់ទីលំនៅ តែតាមពិតគេរស់នៅក្នុងភូមិដដែលទេគ្រាន់តែពេលបោះឆ្នោតនោះវាឆ្លងការិយាល័យគ្នាប៉ុណ្ណោះដោយប្រធានភូមិ ឬប្រធានក្រុមមិនយល់បែរជាលុបឈ្មោះចោល ហើយលោកចង់សួរ លោក នឹម វ៉ាន់សំ ថា បើពេលគេលុបឈ្មោះចេញតើយើងអាចចុះវិញម្តងទៀតបានដែរ ឬ ទេ? ទី ២ ស្មៀនឃុំ បានចុះឈ្មោះអ្នកបោះឆ្នោតឱ្យប្រជាពលរដ្ឋមានប័ណ្ណពតិមាន ហើយប្រជាពលរដ្ឋមួយចំនួនមានប័ណ្ណព័តិមានតែគ្មានអត្តសញ្ញាណប័ណ្ណទេ ដូច្នេះប្រជាពលរដ្ឋក៏ទៅធ្វើទំរង់ ១០១៨ ប៉ុន្តែពេលធ្វើទំរង់១០១៨ អ្នកសរសេរក៏សរសេរឈ្មោះខុសអក្ខរាវិរុទ្ធ លោក ចង់សួរថា តើក្នុងករណីនេះគេអាចបោះឆ្នោតបានដែរ ឬ ទេ? បើបោះមិនបានវិញតើយើងត្រូវធ្វើរបៀបណា?

លោក **ឈុន ប៊ុនរ៉ុង** ជំទប់ទី១ ឃុំពពេល មកពីគណបក្សសម រង្ស៊ី លោកបានសំណូមពរចំពោះការប្តូរការិយាល័យ ដែលបង្កើតថ្មី លេខ ០៧៧៦ ទៅដាក់នៅសាលាឯកើតវិញ ព្រោះប្រសិនបើយើងដាក់នៅឯលិចនោះប្រជាពលរដ្ឋដែលមកពីភូមិនៅឯកើតភាគច្រើនថា វាឆ្ងាយពេកពិបាកក្នុងការមកបោះឆ្នោត ហើយបញ្ហានេះប្រជាពលរដ្ឋភាគច្រើនបានសំណូមពរកាលពីមកចុះឈ្មោះបោះឆ្នោត នៅខែតុលា តែមន្ត្រី CEC គាត់មិនហ៊ានសំរេចទេរងចាំការសំរេចរបស់ថ្នាក់ខេត្ត ។ ដូច្នេះហើយពេលនេះ លោក សំណូមពរឱ្យគណកម្មាការខេត្ត រៀបចំការបោះឆ្នោតធ្វើយ៉ាងម៉េចជុំរុញឱ្យការប្តូរការិយាល័យនេះបាន ដើម្បីឱ្យមានការងាយស្រួលដល់ប្រជាពលរដ្ឋ ។ បញ្ហាមួយទៀតទាក់ ទង នឹងការចែកប័ណ្ណព័តិមានខាងមុខនេះដោយខាង លោក បានធ្វើប្រតិភូកម្មអំណាចទៅឱ្យមេភូមិជាអ្នកជួយចែកប័ណ្ណពតិមាន ប៉ុន្តែកន្លងមក លោក សង្កេតឃើញថា មេភូមិនៅមានការរើសអើងពេលចែកប័ណ្ណព័តិមាន ដូច្នេះលើកនេះ លោក សំណូមពរឱ្យអាជ្ញាធរដែលចូលរួមក្នុងអង្គប្រជុំ ក៏ដូចជាគណកម្មាការរៀបចំការបោះឆ្នោតធ្វើយ៉ាងណាជុំរុញឱ្យមេភូមិទាំងអស់កុំឱ្យរើសអើងពេលចែកប័ណ្ណពតិមាន និង សូមឱ្យមានភាពស្មើភាពដូចដែលបានចែងក្នុងសេចក្តីណែនាំរបស់ គ.ជ.ប ។

លោក **ឡាច ជុំនិត** ជាជំទប់ទី២ ឃុំដូនពេង ស្រុកអង្គរជុំ គណបក្ស ហ៊្វុន សិុនប៉ិច បានមានប្រសាសន៍ថា កន្លងមកនៅក្នុងមូលដ្ឋានរបស់លោកមិនសូវមានបញ្ហាទាក់ទងនិងការបោះឆ្នោតឆ្នាំ២០០៧ នេះទេទាំងការចុះឈ្មោះ និងការចែកប័ណ្ណព័ត៌មានដោយមានសហការគ្នាបានល្អ ។ ប៉ុន្តែកាលពីម្សិលមិញ លោក បានទទួលដំណឹងមួយពី CEC តែមិនទាន់ជាផ្លូវការទេស្តីអំពីបញ្ហារូបថត ដោយនៅភូមិរបស់ លោក អត្តសញ្ញាណប័ណ្ណមានប្រហែលជា ៣៥%ទេ ហើយប្រើតែទំរង់១០១៨ ។ កន្លងមកពេលចុះឈ្មោះបោះឆ្នោត យើងបានហែករូបថតក្នុងប័ណ្ណបោះឆ្នោតទុកបិទនៅទម្រង់ ១០១៨ តែដល់ពេលនេះ CEC ថា មិនទាន់សំរេចទេប្រហែលបញ្ហារូបថត នេះគេមិនកែប្រែក៏មិនដឹង ហើយ លោក ចង់សួរទៅ PEC ថា តើអាចយករូបថតនោះបានឬមិនបាន ករណីបើមិនបាន លោក គិតថា ប្រហែលជាមានការស្មុគស្មាញនៅមូលដ្ឋានរបស់ លោក ព្រោះបញ្ហារូបថត មិនមែនជារឿងងាយស្រួលទេដោយប្រជាពលរដ្ឋមានចំនួនច្រើន ហើយអ្នកដែលប្រឈមមុខដោះស្រាយជូនប្រជាពលរដ្ឋជាអាជ្ញាធរឃុំ-សង្កាត់ គឺវាលំបាក ប៉ុន្តែករណីបើអាចយករូបថតពីប័ណ្ណបោះឆ្នោតចាស់ប្រើបាន គឺគ្មានបញ្ហាទេឡើយ ។

លោក **ជាន់ អឿន** ជំទប់ទី១ ឃុំរើល ស្រុកពួក គណបក្ស ហ៊្វុន សិុនប៉ិច លោក មានចំងល់ ២ ទាក់ទងនឹងបញ្ហាបោះឆ្នោត និងសន្តិសុខនៅឃុំរបស់លោក ។ ការចែកប័ណ្ណពត៌មានវគ្គទី ១ លោក បានចុះចែកផ្ទាល់នៅតាមឃុំហើយ លោក សង្កេតឃើញថា គ្មានសកម្មភាពអ្វីកើតឡើងនៅតាមមូលដ្ឋានឱ្យដោះស្រាយទេ រីឯនៅលើកទី២នេះខាង លោក មិនបានមកទទួលផែនការណ៍យ៉ាងម៉េចទេ តែខាង គ.ជ.ប. បានហៅទៅណែនាំថា យើងនឹងអាចចែកប័ណ្ណព័តិនៅវគ្គទី ២ ហើយសកម្មជនគណបក្សនយោបាយទាំងអស់ នឹងចុះទៅត្រួតពិនិត្យមើលទាំងអស់ចៀសវាងមានបញ្ហា ។ ចំពោះបញ្ហាសន្តិសុខកន្លងមកខាងភូមិ លោក មិនសូវមានបញ្ហាអ្វីទេ ហើយសកម្មជន គណបក្សនយាបាយ ទូទាំងស្រុកពួកទាំងអស់ក៏មិនឃើញមានបញ្ហាអ្វីដែរ ។ ចំណែកបញ្ហាមួយទៀត គឺទាក់ទងនឹងទម្រង់ ១០១៨ ដោយយើងត្រូវមានអត្តសញ្ញាណប័ណ្ណទើបអាចបោះឆ្នោតបាន ប៉ុន្តែអត្តសញ្ញាណប័ណ្ណនៅភូមិ លោក មានតែ ៣០% ប៉ុណ្ណោះដូច្នេះខាង លោក ប្រើទម្រង់ ១០១៨ ទាំងអស់ហើយសព្វថ្ងៃនេះមានការខូចរូបថតច្រើន ទើប លោក ចង់សួរថា បើករណីខូចរូបថតអាចទៅបោះឆ្នោតបានដែរ ឬ ទេ?

លោក **ឪក សេរី សោភក្តិ** បានមានប្រសាស្រ្តថា លោក ភ្ញាក់នឹងតួលេខដែលថា អត្តសញ្ញាណប័ណ្ណបានតែ ៣០%ទេ គឺខុសឆ្ងាយពីតួលេខថ្នាក់ជាតិ ដែលការិយាល័យស្ថិតិរបស់ក្រសួងមហាផ្ទៃបានរាយការណ៍ជូន ឧបសៃល អង្គប្រជុំធំ៧ប៉ុន្មានសប្តាហ៍មុនថាបាន ៩៥% ហើយនេះជាដំណឹងមួយដែលយើងត្រូវតែជំរាបជូនក្រសួងមហាផ្ទៃ ដើម្បីឱ្យលោក ចាត់វិធានការព្រោះវាខុសគ្នាឆ្ងាយណាស់ពីតួលេខថ្នាក់ជាតិ ។ រឿងមួយទៀតដែល លោក ចាប់អារម្មណ៍ គឺទម្រង់ ១០១៨ កន្លងមកមាន បញ្ហាច្រើនណាស់អំពីបញ្ហារូបថត នេះហើយតាមរយៈការជជែកនៅថ្នាក់ជាតិ បញ្ហារូបថតនេះចៀសមិនបានទេ គឺត្រូវតែមានព្រោះនៅ ពេលបោះឆ្នោតមិនដឹងថាសាម៉ីខ្លួនពិតជាឈ្មោះអញ្ចឹងមែនឬអត់ ។

លោក **នឹម វ៉ាន់សំ** បានឆ្លើយតប នឹងសំនួរខាង លោក ស្លក្រាម ថា តាមនិតិវិធី ការបាត់ឈ្មោះពីក្នុងបញ្ជីដល់ទៅ ៣០% នេះមិនមែនជារឿងធម្មតាទេ ហើយតាមនិតិវិធីចំពោះការចុះឈ្មោះបោះឆ្នោតរហូត មកដល់ពេលនេះហើយ គឺ PEC មិនអាចចុះឈ្មោះបានទៀតទេ ។ ចំពោះការបាត់ឈ្មោះដល់ទៅ ៣០% នេះ លោក មិនទាន់ជឿតួលេខនេះ ទេព្រោះតាមធម្មតាមុន នឹងលុបឈ្មោះមនុស្សម្នាក់ ស្មៀនឃុំត្រូវបំពេញទំរង់បែបបទមួយចំនួន ហើយ NEC ក៏មិនចេះតែលុបចោល ដោយគ្មានទម្រង់ពីមូលដ្ឋានដែរ លោក បានសូមតួលេខនេះដើម្បីខាង លោក នឹងស្រាវជ្រាវបន្តទៀតថា តើមូលហេតុអ្វីបានជាលុប ។ តាម ធម្មតាបាត់ឈ្មោះគេម្នាក់មិនមែនជារឿងធម្មតាទេព្រោះយើងធ្វើការប្រយ័ត្នប្រយែងណាស់ទាំង NEC, PEC ព្រមទាំងស្មៀនឃុំ ហើយមុននឹងលុប គជប ត្រូវសិក្សា

ច្បាស់លាស់ណាស់ ដូចជាបើសិនករណីស្លាប់ត្រូវមានសំបុត្រមរណភាព គឺមិនមែនលុបតាមតែនឹកឃើញនោះទេ ។ ស្មៀនជាមន្ត្រីចុះឈ្មោះ ហើយពេលដែលធ្វើខុសនិតិវិធី ស្មៀននោះ នឹងទទួលទណ្ឌកម្មតាមច្បាប់ដែលបានដាក់ ពី គ.ជ.ប មកមិនមែនចេះតែលេងសើចផ្តេសផ្តាស់នោះទេ ។ បន្ទាប់មក លោក បានឆ្លើយតបនឹងសំនួរដែលសួរថា ចំពោះទម្រង់១០១៨ ខុសអក្ខរាវិរុធ តើបោះឆ្នោតបានដែរឬទេ? ពីរថ្ងៃទៀតប្រហែលជាថ្ងៃទី ៨ យើងនឹងចាប់ផ្តើមចែកប័ណ្ណព័តិមានហើយប័ណ្ណព័តិមានដែលចែកលើក ទី២ នេះ គឺវាមានឈ្មោះនិងទិន្នន័យដូចនៅក្នុងបញ្ជីផ្លូវការ ។ ដូច្នេះបើសិនជាអស់លោកបានទទួលបានប័ណ្ណព័តិមាន ហើយអស់ លោក ត្រូវតែតម្រូវទៅតាមប័ណ្ណព័តិមាននោះទៅដើម្បីបានទៅបោះឆ្នោត ចំពោះសំនួរដែលថា តើអាចទៅបោះឆ្នោតបានដែរឬទេ? បើអត្តសញ្ញាណប័ណ្ណចេញមកខុស ឬ មាន ១០១៨ ហើយតែចេញព័តិមានមកខុស លោក ឆ្លើយថា បានព្រោះ ទី១ បើ អត្តសញ្ញាណប័ណ្ណចេញមកខុសពីប័ណ្ណព័តិមានសូម លោក យករូបថត ២សន្លឹក ទំហ 4x6 ទៅបិទ នឹង១០១៨ ដោយធ្វើតំរូវទៅតាម ប័ណ្ណព័តិមាន គឺអស់ លោក នឹងអាចដោះស្រាយបញ្ហាបោះឆ្នោតនេះបាន ។ ដោយឡែកចំពោះបញ្ហាអត្តសញ្ញាណប័ណ្ណ គឺអស់ លោក អាចទៅជួបប៉ូលីសឱ្យដោះស្រាយពេលចប់បោះឆ្នោត ។ ចំពោះសំនួររបស់លោក **ឈុន ប៊ុនរ៉ុង** អំពីការផ្លាស់ប្តូរការិយាល័យ លោក បានមានប្រសាសន៍ថា រហូតមកដល់ពេលនេះ លោក ជឿថា ការិយាល័យមួយចំនួនមានការបាត់បង់ដោយសារស្ថានភាពនៅស្រុកយើងមានការលក់ដូរដីធ្លីផ្ទះសំបែង ។ តាមនិតិវិធីរបស់ គជប ថា ឱ្យតែនៅឆ្ងាយពីគ្នា ១០០ម៉ែត្រ ពីទីតាំងចាស់គឺអាចដាក់ទីតាំងថ្មីជូនបាន ក៏ប៉ុន្តែបើសិនជាឆ្ងាយពេកចាប់ពី ១០០ ម៉ែត្រឡើងទៅប្រជាពលរដ្ឋដែលចាំថា ធ្លាប់មកបោះឆ្នោតនៅកន្លែងចាស់មិនអាច រកកន្លែងថ្មីឃើញទេ ដូច្នេះបើ ១០០ ម៉ែត្រយើងអាចរំកិល ឬ ផ្លាស់ប្តូរទីតាំងចាស់មកកន្លែងដែលមានសុវត្ថិភាពបាន ដូចជាយើងអាចសង់ជារោងដើម្បីឱ្យប្រជាពលរដ្ឋទៅបោះឆ្នោតបាន កាលណាយើងដាក់ឆ្ងាយពេកប្រជាពលរដ្ឋមិនអាចរកទីតាំងឃើញទេ ។ ហើយ លោក ក៏ស្នើសុំឱ្យខាងគាត់ទាក់ទងមកខាងលោកផ្ទាល់ដោយលំអិតថា ការិយាល័យ ០៧៧៦ នៅឯណា និងម្យ៉ាងទៀតក្នុងប័ណ្ណព័តិមាន យើងក៏ដាក់ឈ្មោះការិយាល័យដែរ ។ ចំពោះការិយាល័យភ្លោះ គឺមិនមានទៀតទេ ហើយពីមុនយើងមានការិយាល័យភ្លោះដោយសារយើងចុះលើសចំនួន ៧០០នាក់ ដែលខុសពីនិតិវិធី ។ ទាក់ទង នឹងការចែកប័ណ្ណព័តិមាន មានបញ្ហារើសអើងនោះ លោក សូមកុំឱ្យមានអីព្រោះនៅលើកទី ១ ក៏មានការទិះតៀនដូចគ្នាអំពីបញ្ហានេះដែរ ប៉ុន្តែនៅលើកទី២ នេះ គ.ជ.ប. ដោយមានការឧបត្ថម្ភពី UNDP បានបោះសៀវភៅគាវរកិច្ចរបស់ភូមិ ដើម្បីជំរាបទៅភូមិឱ្យគាត់ប្រកាន់ចរិកអព្យាក្រិតមួយក្នុងការចែកប័ណ្ណព័តិមាននេះ ហើយសៀវភៅនោះក៏បានទៅដល់ភូមិដែរ ដូច្នេះលោកសង្ឃឹមថា នៅលើកទី២ នេះ នឹងមិនមានការរើសអើងទេ តែបើក្នុងករណីមាន សូមខាងឃុំផ្តល់ព័តិមាននេះជំរាបជូនខាង លោក ឱ្យបានជ្រាបផង ។ ចំពោះសំនួររបស់ លោក ឡាច ជុំនិត នៅស្រុកអង្គរជុំ គឺដូចលោក ឱក សេរី សាភក្តិ៍ បានបញ្ជាក់រួចហើយថា បញ្ហារូបថត ចាំបាច់ត្រូវតែមាន ។ ដោយសារសល់តែ ២ខែទៀត យើងបោះឆ្នោតមិនដឹងថាទៅរកនៅទីណាទេ ដូច្នេះខាង លោក បានសំរួលថា រូបថតណាក៏បានឱ្យតែមើលមុខស្គាល់ថា អ្នកហ្នឹងពិតជាឈ្មោះអញ្ចឹងមែនប៉ុន្តែសូមកុំយករូបថតពីក្មេងពេកព្រោះមន្ត្រីការិយាល័យពិបាកមើល ។ ដូច្នេះហើយមិនចាំបាច់តែរូបថត 4x6 ទាំងអស់ទេព្រោះប្រហែលជាពិបាករកណាស់តាមមូលដ្ឋាន ។ ចំណែកឯសំនួររបស់ លោកជំទប់ទី ១ ខាងឃុំរើល ស្រុកពួកនេះ លោក នឹម វ៉ាន់ សំ បានឆ្លើយតបថា មុននឹងចែកប័ណ្ណព័តិមានប្រហែលជាថ្ងៃទី ២៧ កន្លងមក PEC បានប្រជុំ ជាមួយ CEC ក្រុមចែកប័ណ្ណព័តិមាន និងមេឃុំ ហើយរួច PEC បានសំរេចបង្កើតជាក្រុមមួយដែលក្រុមនោះមានមន្ត្រី CEC ខាង លោក ជាប្រធានក្រុមក្រុមប្រឹក្សាឃុំ-សង្កាត់ជាសមាជិក និងអង្គការក្រៅរដ្ឋាភិបាលព្រមទាំងមេភូមិក៏ចូលរួមដែរ ។ ចាប់ពីថ្ងៃ ០៨ ខែ កុម្ភះ រហូតដល់ថ្ងៃ ០៨ ខែ មិនា ក្រុមនេះបានរៀបប្រតិទិនមួយសំរាប់ការចុះចែកប័ណ្ណព័តិមានថា តើថ្ងៃណាគេចែកនៅឯណា ហើយយើងអាចទាក់ទងគេគ្រប់ពេលវេលានៅ

CEC ព្រមទាំងក្រុមនេះក៏មានបិទផ្សាយថា ថ្ងៃនេះគេចែកនៅភូមិណាហើយមានប៉ុន្មានការិយាល័យនៅទីនេះផងដែរ ។ ទាក់ទងនឹងទម្រង់ ១០១៨ កន្លងមក PEC បានធ្វើការល្អជាមួយគ្នាគ្រប់គណបក្សនយោបាយ ។ យើងក៏មានខាង UNDP បានមកសិក្សា និងចុះមើលការខុសត្រូវ ហើយគាត់ថែមទាំងបានជូនខាង លោក នូវទម្រង់ ១០១៨ មួយម៉ឺនច្បាប់ទៀត សំរាប់ចែកជូនប្រជាពលរដ្ឋ ព្រោះ គ.ជ.ប. ផលិតមកមានភាពយឺតយ៉ាវម្យ៉ាងទៀតគណបក្សនយោបាយនៅខេត្តសៀមរាប ក៏ មិនរើសអើងដែរ គឺគេបានជួយផ្តល់ទម្រង់ ១០១៨ ដល់ក្រុមប្រឹក្សាឃុំដើម្បីឱ្យគាត់ចេញជូនប្រជាពលរដ្ឋ ហើយការងារនេះយើងមិន បានប្រកាន់ទេព្រោះទម្រង់ ១០១៨ មិនចាំតែយកពី គ.ជ.ប. គឺយើងអាចយកវាទៅហ្វូតូកូពីជូនប្រជាពលរដ្ឋបំពេញ បន្ទាប់មក ឃុំចុះហត្ថលេខានិងបោះត្រាលើរូបថតបានហើយ ។

លោក **ឱក សេរី សោភក្តិ៍** បានរំលឹកនៅចំណុចពីរ ទី១ ស្តីអំពីការិយាល័យបោះឆ្នោត កន្លងមកនៅខេត្តខ្លះយើងបានសង្កេតឃើញថា មានការទិះទៀនអំពីការិយាល័យបោះឆ្នោតដែលដាក់នៅតាមផ្ទះឯកជន ហើយខាង គ.ជ.ប. នៅថ្នាក់ជាតិ ក៏បានលើកបញ្ហានេះដែរ ។ ដូច្នេះ លោក សូមឱ្យ PEC នៅគ្រប់ខេត្តទាំងអស់ខំធ្វើយ៉ាងណាជៀសវាងកុំឱ្យដាក់នៅទីកន្លែងដែលនាំឱ្យមានការទិះទៀន និងបាត់លក្ខណៈឯករាជ្យភាព និងអព្យាក្រិតភាពរបស់ការិយាល័យបោះឆ្នោត ។ យើងដឹងហើយថា ធ្វើបែបនេះជាការលំបាកណាស់ ប៉ុន្តែប្រសិនបើករណីពិបាក នឹងរកកន្លែងផ្សេងនោះ លុះត្រាតែគណបក្សនយោបាយនៅឃុំនោះ ចុះហត្ថលេខាព្រមព្រៀងជាមួយគ្នា ដើម្បីកុំឱ្យចេះតែថា ព្រមព្រៀងហើយយកទៅតវ៉ានៅថ្នាក់ជាតិទៀតដូចជាមិនបានព្រមព្រៀងសោះ ។ បញ្ហាមួយទៀតដែល លោក ចង់ជំរាបដែរថា ការចែកប័ណ្ណព័តិមានលើកទី២ នេះគឺយើងធ្វើពីថ្ងៃទី ០៨ ខែ កុម្ភៈ រហូតទៅដល់ថ្ងៃទី ០៨ ខែ មិនា ដូច្នេះកៀកនឹងការបោះឆ្នោតខ្លាំងមែនទែន ។ ហើយនៅពេលយើងបញ្ចប់ការចែកប័ណ្ណព័តិមាននៅសល់តែមួយសប្តាហ៍ទេ នឹងចាប់ផ្តើមយុទ្ធនាការឃោសនាបោះឆ្នោតដែលប្រព្រឹត្តនៅថ្ងៃទី ១៥ ខែ មិនា ។ ហេតុនេះហើយបានជានៅថ្នាក់ជាតិយើងបានធ្វើការប្រជុំគ្នាដល់ទៅ ២ ឬ ៣ដង នៅពេលដែលយើងបញ្ចប់ការចែកប័ណ្ណព័តិមាននៅ ខែ សីហា ទៅ ដើម្បីធ្វើយ៉ាងណាយកលក្ខណៈខ្វះខាតយកមកជជែកគ្នា និងកែខៃ ។ ដូចនេះហើយបានជា ខប់សែល នៅថ្នាក់ជាតិបានលើកសំណើរទៅ គ.ជ.ប និង UNDP សូមឱ្យមានការចូលរួមពីអង្គការសង្គមស៊ីវិលនានាដើម្បី នឹងចូលរួមបើកយុទ្ធនាការប្រកបដោយតម្លាភាព ហើយបានជា លោក សូមឱ្យយកចិត្តទុកដាក់ព្រោះបើសិនជាមានបញ្ហានៅកន្លែងណាមួយដោយសារការចែកកៀកជាមួយយុទ្ធនាការឃោសនាការបោះឆ្នោតខ្លាំង បញ្ហាហ្នឹងអាចក្លាយទៅជាទំនាស់នយោបាយ ហេតុដូចនេះសូមមេភូមិទាំងអស់តោងតែអនុវត្តកិច្ចការនេះជាមួយគណកម្មាការឱ្យមានលក្ខណៈចំហ តម្លាភាព និងអព្យាក្រិតព្រោះប្រសិនបើមានបញ្ហាអ្វី ប្រហែលជាយើងអាចកែខៃស្ថានការណ៍លំបាកក្នុងនៅពេលនោះបាន ប៉ុន្តែយើងជឿជាក់ថា អ្វីដែលបានជជែកមកបង្ហាញឱ្យឃើញថា យើងទាំងអស់គ្នាពិតជាមានមនសិការយល់ច្បាស់ពីបញ្ហាអស់នេះ ហើយ យើងខំធ្វើយ៉ាងណាឱ្យការចែកលើកទី២ នេះមានលក្ខណៈតម្លាភាពអាចពិនិត្យបានទាំងអស់គ្នាសូម្បីតែគណបក្សនយោបាយក៏ អាចជួយពិនិត្យដែរព្រោះឥលូវនេះចូលរួមបោះឆ្នោតជាផ្លូវការហើយ ។

លោក **ឈុន ប៊ុន រ៉ុង** ជំទប់ទី១ ឃុំពពេល មកពីគណបក្សសម រង្ស៊ី បានមានប្រសាសន៍ថា នៅក្នុងឃុំរបស់ លោក ពីដើមឡើយមានការិយាល័យសរុបទាំងអស់ចំនួន១០ ប៉ុន្តែថ្មី១នេះគេទើបបង្កើតនូវការិយាល័យថ្មីមួយទៀត លេខ ៧៧៦ មានទីតាំងស្ថិតនៅក្បែរការិយាល័យលេខ ៥៦៩ ដូចនេះលោកក៏ដូចជាប្រជាពលរដ្ឋភាគច្រើននៅក្នុងឃុំរបស់លោកស្នើសុំអោយដាក់ការិយាល័យលេខ ៧៧៦ ថ្មីនេះអោយនៅឆ្ងាយពីការិយាល័យចាស់ ហើយសំណូមពរអោយដាក់នៅជិតកន្លែងដែលគេបោះឆ្នោតវិញ ដើម្បីផ្តល់ការ

ងាយស្រួលដល់ប្រជាពលរដ្ឋនៅពេលបោះឆ្នោត ព្រោះនៅអាណត្តិមុនៗមានប្រជាពលរដ្ឋភាគច្រើនពុំបានចូលរួមធ្វើការបោះឆ្នោតឡើយ ។

លោក **មា ភារុន** ជាក្រុមប្រឹក្សាឃុំសាលាកំរើកមកពី គណបក្ស នរោត្តម រណឫទ្ធិ ដែលជាគណបក្សថ្មីបំផុតទើបនឹងបង្កើតនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៦ នេះ បានសំដែងនូវផលវិបាកនៃការរៀបចំមុខងារដែលកើតមាននៅក្នុងការបោះឆ្នោតអាណត្តិថ្មីនេះដោយសារការផ្តាច់ចេញពីគ្នារវាងគណបក្ស ហ៊្វុន ស៊ិនប៉ិច និងគណបក្ស នរោត្តមរណឫទ្ធិ ។ លោក បានបន្តទៀតថា លោកតំណាងអោយជិតមួយរយឃុំសំណូមពរឱ្យ លោក នឹម វ៉ាន់សំ ជាពិសេសជួយនាំពាក្យរបស់ លោក ទៅដល់ គ.ជ.ប ផង ពាក់ព័ន្ធនូវបញ្ហាមួយចំនួនដូចជា បញ្ហាការរៀបចំការសង្កេតការណ៍ដែលពីមុនមកមិនមានប្រកាន់ក្នុងឃុំទេ ប៉ុន្តែឥលូវនេះគេតំរូវអោយជ្រើសរើសភ្នាក់ងារសង្កេតការណ៍ នៅតាមឃុំនីមួយៗផ្ទាល់តែម្តង ចំពោះបញ្ហានេះជាការលំបាកមួយព្រោះថា សំរាប់ធនធានមនុស្ស គឺមានគ្រាប់គ្រាន់តែពួកគេភាគច្រើនមិនមានប័ណ្ណបោះឆ្នោតតាមការកំណត់របស់ គ.ជ.ប ឡើយ ។ លោក ក៏បានបញ្ជាក់បន្ថែមថា ក្នុងនាមជាតំណាងឃុំសាលាកំរើក ខេត្តសៀមរាប លោក សូមជំរាបថា ខេត្តនេះពុំអាចរើសបានឡើយព្រោះថា ភាគច្រើនជ្រើសរើសបានពុំពេញសិទ្ធិ ប៉ុន្តែការបំរុងនោះនៅមានភាពខ្វះចន្លោះ ហេតុដូច្នេះ លោក សំណូមពរទៅដល់ គជប ក៏ដូចជាប្រធាន PEC ដើម្បីធ្វើយ៉ាងណាអោយអង្គការសង្គមស៊ីវិលមានវិធានការណ៍ទៅលើការិយាល័យមួយចំនួនដែល គណបក្ស នរោត្តមរណឫទ្ធិ រើសអ្នកសង្កេតការណ៍ពុំបាននោះហើយ ក៏ធ្វើការសំណូមពរទៅអង្គការតែម្តងធ្វើយ៉ាងណាអោយបញ្ជូនអ្នកសង្កេតការ សង្គមស៊ីវិលបើជាសមាជិកអង្គការសហប្រជាជាតិកាន់តែប្រសើរដើម្បីងាយស្រួលសំរាប់ការត្រួតពិនិត្យក្នុងការរាប់សន្លឹកឆ្នោត ។ ជាចុងក្រោយ លោក ក៏បានសំណូមពរបន្ថែមទៀតថា ចំពោះការិយាល័យមួយចំនួនតូចដែលពុំអាចរើសភ្នាក់ងារពេញសិទ្ធិបាននោះ PEC អាចអោយមានកំលាំងតំណាងខេត្តទាំងនេះបន្ថែមបានដែរ រឺទេ? ព្រោះ លោក ពុំអាចរៀបចំទាន់ពេលវេលាបានទេ ។

លោក **ឈន គីមឃន** ជាក្រុមប្រឹក្សាឃុំថ្នល់ក្រោម គណបក្ស សម រង្ស៊ី លោក បានមានប្រសាសន៍ ស្នើសុំអោយ លោក នឹម វ៉ាន់ សំ ធ្វើការបកស្រាយបញ្ហាសំខាន់ៗចំនួនពីរ ដែលបញ្ហាទី១ គឺនៅក្នុងចំណោម៥០នាក់ដែល លោក បានរើសអ្នកសង្កេតការណ៍នោះមានបាត់ឈ្មោះទៅដល់ ១៥នាក់ ។ បញ្ហាទី២ ពាក់ព័ន្ធ នឹងបញ្ហាអ្នកចុះឈ្មោះថ្មី ដូចជាក្មេងគ្រប់អាយុ ១៨ឆ្នាំ ទៅចុះឈ្មោះដោយមានចុងសន្លឹកត្រឹមត្រូវនិងមានអ្នកដឹងឮច្បាស់លាស់ហើយ ប៉ុន្តែស្រាប់តែនៅពេលដែលលោកចុះសង្កេតការណ៍ លោក ពុំឃើញមានឈ្មោះទាំងនោះនៅក្នុងបញ្ជីឈ្មោះរបស់សាលាឃុំឡើយ ដូចនេះតើឈ្មោះទាំងនេះអាចមានសិទ្ធិបោះឆ្នោតដែរឬទេ?

លោក **នឹម វ៉ាន់សំ** ប្រធាន PEC ខេត្តសៀមរាប បានមានប្រសាសន៍ថា ចំពោះបញ្ហាសំណូមពរសូមផ្លាស់ប្តូរទីតាំងការិយាល័យនេះជាបញ្ហាលំបាកប្រសិនបើពួក លោក ត្រឹមតែធ្វើការឆ្លើយឆ្លងពុំបានដឹងច្បាស់ទេ ដូចនេះ លោក បានអះអាងថា លោក នឹងបញ្ជូនភ្នាក់ងាររបស់ លោក ដែលជាសមាជិក PEC នេះចុះធ្វើការស្រាវជ្រាវជាក់ស្តែងនៅការិយាល័យលេខ ៧៧៦ នេះតែម្តង ហើយសន្យាថា នឹងឆ្លើយតបជូនដល់ លោក វិញមិនអោយហួសពីថ្ងៃខានស្អែកនេះទេ ព្រោះ លោក ត្រូវមើលពីភាពជាក់ស្តែងដោយសារតាមធម្មតាប្រសិនបើគេចង់បង្កើតការិយាល័យមួយនោះ គេតំរូវអោយក្រុមប្រឹក្សាឃុំធ្វើការស្នើសុំទៅ គ.ជ.ប ដើម្បីបង្កើតការិយាល័យមួយសំរាប់ខ្លួនឯង ប៉ុន្តែ លោក គិតថា ប្រហែលជាការិយាល័យនេះចុះឈ្មោះលើសដែលជាហេតុត្រូវគេកាត់ចោល ។ ដោយឡែកកន្លងមកគេមិនដែលប្រកាន់ថា ក្នុងភូមិមួយត្រូវតែមានការិយាល័យមួយនោះទេ ដូចជាការិយាល័យខ្លះអាចបំរើអោយភូមិចំនួនបីបួនជាពិសេសនោះ គឺថាជាទូទៅដើម្បីបង្កើតការិយាល័យមួយគេត្រូវមានមនុស្សយ៉ាងតិចចំនួន ៥០នាក់ ឡើងទៅ ដើម្បីជៀសវាងការចំណាយថវិកាច្រើនឥតប្រយោជន៍ ហើយបើករណីមានមនុស្សច្រើនជាងការកំណត់គេត្រូវពុះការិយាល័យនោះជាពីរទៀត ដូចនេះភូមិ

មួយចំនួនដែលនៅឆ្ងាយនោះ គឺនៅតែឆ្ងាយដដែល ហើយប្រសិនបើចង់ស្នើសុំការិយាល័យមួយសំរាប់ភូមិមួយនោះត្រូវមានសំណើរពីក្រុមប្រឹក្សាឃុំ ដែលសំណើត្រូវមុនការចុះឈ្មោះ បោះឆ្នោត តែទោះជាយ៉ាងណាក៏ដោយ លោក បានសន្យាថា នឹងព្យាយាមដោះស្រាយនូវបញ្ហាដោយបញ្ជូនសមាជិកក្រុមរបស់ លោក ទៅធ្វើការស្រាវជ្រាវជាក់ស្តែងអំពីបញ្ហានេះ ។

លោក **នឹម វ៉ាន់សំ**ក៏បានបន្តទៀតថា ឆ្លើយតបតាមការសំណូមពររបស់ លោក មកពីគណបក្ស នរោត្តម រណរិទ្ធិ លោកបានមានប្រសាសន៍ថា តាមធម្មតាភ្នាក់ងារសង្កេតការត្រូវមានឯកសារចំនួនបី លិខិតលេខ ១០០៧ លិខិតបញ្ជាក់ពីក្រសួងមហាផ្ទៃ និងលិខិតបញ្ជាក់ពីក្រុមប្រឹក្សាឃុំថា បានមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត ដូចនេះនៅក្នុងសំនួររបស់ លោក ដែលសួរថា តើលោកអាចយកមនុស្សខាងក្រៅមកបានដែររឺទេនោះ លោក មិនអាចផ្តល់នូវចំលើយបានទេព្រោះវាទំនងជាខុសនឹងនីតិវិធី ។ ចំពោះបញ្ហា លោក **ឈន គឹមឃន** នៅស្លក្រាម លោក បានស្នើសុំអោយសួរទៅស្មៀនដើម្បីបញ្ជាក់បន្ថែមអំពីឈ្មោះដែលបានបាត់នោះ ហើយ លោក ក៏បានធានាថា នឹងជួយស្រាវជ្រាវរកឈ្មោះទាំងនេះជូនដែរ ដោយសន្យាផ្តល់នូវចំលើយនៅថ្ងៃ ទី៨ ខានស្អែកនេះ ។ លោក បញ្ជាក់ប្រាប់ថា ប្រសិនបើមានប្រកាន់ដៃតែគ្មានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតទេនោះមិនអាចចូលរួមបោះឆ្នោតបានទេ ដូចនេះទាល់តែមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងអត្តសញ្ញាណច្បាស់លាស់ទើបអាចបោះឆ្នោតបាន ។

លោក **ហេង លី** ជំទប់ទី ១ ឃុំក្បៀនសង្កែ គណបក្សសម រង្ស៊ី បានបង្ហាញពីវិសាលភាពរបស់ស្រុកសូទ្រនិគម ទាំងមូលដោយយល់ឃើញថា នៅឆ្នាំ១៩៩៣ និង១៩៩៨ មានការប្រទូស្តរាយគ្នារហូតដល់មានការបាញ់សំលាប់គ្នាជាបន្តបន្ទាប់ ហើយ ក្រោយមកទៀតរាជរដ្ឋាភិបាលរបស់យើងក៏មានឆន្ទះចង់ដោះស្រាយបញ្ហាជំលោះផ្ទៃក្នុងនិងការកាត់បន្ថយអំពើហឹង្សារហូតដល់ការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ ២០០៣ ។ ឃើញថាទោះគណបក្សសម រង្ស៊ី ជាគណបក្សប្រឆាំងក៏បានឈរឈ្មោះជាបេក្ខជនប្រកួតប្រជែងនៅក្នុងស្រុកសូទ្រនិគមដែលមាន ១០ឃុំ នោះគឺបានជំទប់ចំនួន ៩ឃុំ ដែរ ជាពិសេសក្រោយពីគណកម្មាការក្រុមប្រឹក្សាឃុំ-សង្កាត់ បានរៀបចំរួចនៅក្នុងស្រុកទាំងមូលក៏មានការពិភាក្សាសំរបសំរួលគ្នាក្នុងការអនុវត្តការងារបំរើប្រជាពលរដ្ឋ ។ រហូតមកដល់បច្ចុប្បន្ននេះទៀតនៅឆ្នាំ ២០០៦ ក្រោយពីការដាក់អោយមានភ្នាក់ងារឯកជន ក៏ដូចជាភ្នាក់ងារសង្កេតការណ៏នោះឃើញថា ទាំងគណកម្មាការរៀបចំការបោះឆ្នោតឃុំ-សង្កាត់ និងគណកម្មាការខេត្ត-ក្រុងរៀបចំការបោះឆ្នោត មានសម្បទានគ្នាទៅវិញទៅមក និងសំរបសំរួលចចារគ្នាដោយមិនយកជំលោះប្តឹងផ្តល់គ្នាជាធំនោះឡើយ ដែលទាំងនេះជាទស្សនៈរបស់ពួកគេទាំងអស់គ្នាក្នុងគោលបំណងចង់បានលទ្ធិប្រជាធិបតេយ្យបោះឆ្នោតដោយសេរី និងយុត្តិធម៌ ។ ប៉ុន្តែទោះជាយ៉ាងណា ក៏ដោយក៏នៅមានកង្វះខាតមួយចំនួនដូចជាទី១ ទំរង់ ១០១៨ ដែលកន្លងមកគណកម្មាការរៀបចំការបោះឆ្នោតបានជំនួយជាម៉ាស៊ីនថតសំរាប់ថតរូបជូនប្រជាពលរដ្ឋដើម្បីយកមកបិតនូវទំរង់លិខិត ១០១៨នេះ តែនៅឆ្នាំ ២០០៦ នេះគណៈកម្មាការរៀបចំការបោះឆ្នោតពុំមានឧបត្ថម្ភការថតរូបនេះទៀតឡើយ ហើយមានតែតាមគណបក្សនីមួយៗថតជូនទៅវិញ ដូចនេះប្រជាជនមួយចំនួនដែលគាត់ប្រកាន់អព្យាក្រឹតភាពពុំមានលទ្ធភាពក្នុងការទទួលបានរូបថត ហេតុដូច្នេះ លោក បានសុំសួរទៅក្រុមគណកម្មាការរៀបចំការបោះឆ្នោតថា តើពួក គជប អាចមានលទ្ធភាពឬអនុសាសន៍យ៉ាងណា ដើម្បីជួយអោយប្រជាពលរដ្ឋមានរូបថតសំរាប់បិតលើទំរង់ ១០១៨ នេះសំរាប់មានសិទ្ធិបោះឆ្នោត ។ ទី២ ការរើសអើង ដូចជាការបោះឆ្នោតជ្រើសរើសមេភូមិ អនុប្រធានភូមិ សមាជិកភូមិកន្លងមកពីមុនមកមានលក្ខណៈជាអសកលដែលថែងថា គណបក្សណាដែលមានសំលេងក្រុមប្រឹក្សាឃុំច្រើនជាងគេនោះជាអ្នកឈ្នះហើយមានសិទ្ធិឈរឈ្មោះជាបេក្ខជនឃុំទៀត ជាពិសេស នៅពេលនេះគណកម្មាការរៀបចំការបោះឆ្នោតបានផ្ទេរសិទ្ធិទៅពួកគេដោយចាត់ទុកថា ជាបុគ្គលអព្យាក្រឹតក្នុងការចែកជូនពត៌មានអំពីការបោះឆ្នោតទៅដល់ប្រជាពលរដ្ឋតាមឃុំនីមួយៗ តែទោះយ៉ាងណាក្តី លោក មានការព្រួយបារម្ភខ្លាចក្រែងពួកគេពុំបាន

បញ្ជូនពត៌មានផ្សេងៗ តួយ៉ាងដូចជាសៀវភៅសេចក្តីណែនាំអំពីអព្យាក្រឹតភាពរបស់មេភូមិនេះទៅដល់ថ្នាក់ភូមិ ដូចនេះ លោក សូមសំណូមពរដល់គណកម្មាការរៀបចំការបោះឆ្នោតជួយសំរួលអោយសេចក្តីណែនាំរបស់ គ.ជ.ប បានផ្សព្វផ្សាយដល់ថ្នាក់ភូមិផង ព្រោះកន្លងមកឱ្យដល់ថ្នាក់ឃុំ ចំណែកឯមេភូមិពុំបានទទួលឡើយ ។

លោក**ឱក សេរី សោភក្តិ៍** បានស្នើសុំឱ្យ លោក **ហេង លី** បញ្ជាក់ប្រាប់ឈ្មោះឃុំដែល លោក កំពុងតែនិយាយសំដៅលើអោយបានចំៗតែម្តងដើម្បីងាយស្រួលដល់គណៈកម្មាការធ្វើការចុះទៅស្រាវជ្រាវ ហើយ លោក ក៏បានស្នើសុំបន្ថែមអោយពិនិត្យមើលពីការបរិច្ឆេទដែលឃុំបានទទួលសៀវភៅណែនាំរៀបចំដោយអង្គការ UNDP នោះផងព្រោះថា ជួនកាលខាងថ្នាក់ឃុំគាត់ក៏ទើបទទួលបានសៀវភៅណែនាំនោះក្នុងពេលថ្មីៗនេះដែរ ។

លោក **ឡុក វួន** មេឃុំស្រណាល ស្រុកក្រឡាញ់ គណបក្ស ប្រជាជន បានចូលរួមបញ្ចេញមតិអំពីការចែកប័ណ្ណ ពតិមានលើកទី១ នោះថា ក្រុមប្រឹក្សាឃុំ និងមេភូមិជាអ្នកចុះផ្ទាល់ ហេតុដូចនេះសំរាប់អ្នកដែលមិនបានទទួលបានប័ណ្ណព័តិមាននេះប្រ ហែលជាពួកគេអវត្តមាន ហើយប័ណ្ណពតិមាននោះត្រូវផ្ញើទុកនៅនឹងមេភូមិរឺសាច់ញាតិរបស់គាត់ ។ លោក បានបន្តទៀតថា ការព្រួយបារម្ភពីបញ្ហាប្រឈមនឹងការបោះឆ្នោតនៅក្នុងឃុំរបស់ លោក គឺអត្តសញ្ញាណប័ណ្ណពុំទាន់បានចេញដោយសារមិនទាន់បានចុះហត្ថលេខា ឬអាចចុះហើយតែមិនទាន់បញ្ជូនទៅដល់ឃុំ បើពិនិត្យមើលពីអត្តសញ្ញាណប័ណ្ណ និងប័ណ្ណបោះឆ្នោតឃើញថា ទំរង់ ១០១៨ នៅសល់ជាង ១០០០នាក់ និងតុល្យភាពអ្នកដែលបានរូបថតអត្តសញ្ញាណប័ណ្ណ ក៏មានជាង ១០០០នាក់ ដែរ ដូច្នេះនៅមានកង្វះខាតច្រើនទៀត ។ លោក ក៏បានបង្ហាញមកវិញអំពីបញ្ហាសៀវភៅណែនាំអំពីអព្យាក្រឹតរបស់មេភូមិថា គណកម្មាការឃុំទទួលបានសៀវភៅនេះ នៅក្នុងការប្រជុំដែលរៀបចំនៅស្នងការហើយគណកម្មាការឃុំទាំងអស់នេះក៏បានធ្វើប្រតិទិនប្រជុំមេភូមិមួយជាតំណាងឱ្យអង្គការនានា និងគណបក្សនយោបាយដោយបានចែកជូននូវសៀវភៅនោះដល់មេភូមិផ្ទាល់ និងរក្សាទុកសៀវភៅនេះចំនួនពីរច្បាប់នៅក្នុងសាលាឃុំដើម្បីអោយមេឃុំដឹងផងងាយស្រួលតាមដានគ្រប់គ្រងការអនុវត្តការងាររបស់មេភូមិ ។

លោក **ឱក សេរី សោភក្តិ៍** បានមានប្រសាសន៏ថា គោលការណ៏របស់ គ.ជ.ប នៃការចែកប័ណ្ណពតិមាននេះទៅដល់ទីកន្លែងជាជាងការអោយប្រជាពលរដ្ឋអញ្ជើញមកមើលពត័មានដោយខ្លួនឯងនោះទទួលបានការគាំទ្រនិងការសរសើពីមតិអន្តរជាតិច្រើន ប៉ុន្តែនៅពេលអនុវត្តជាក់ស្តែងកើតមាននូវបាតុភាពមួយចំនួនដោយសារមានការច្រឡំថា ប័ណ្ណពត័មានទាំងនេះជាប័ណ្ណបោះឆ្នោត ហើយមានមេភូមិខ្លះបានយកប័ណ្ណទាំងនេះទៅទុកក្នុងផ្ទះរបស់គាត់ដោយមិនព្រមផ្សព្វផ្សាយដំណឹងបន្តទៀតឡើយ ។ ដោយយល់ឃើញនូវការលំបាកទាំងនេះ នៅខែ កញ្ញា តុលា និងវិច្ឆិកាឆ្នាំ ២០០៦នេះ ខប់សែល បានរៀបចំការប្រជុំប្រចាំខែដើម្បីស្វែងរកដំណោះស្រាយសំរាប់ចំណុចអវិជ្ជមានទាំងនេះ ក្នុងគោលបំណងជំរុញការបោះពុម្ភសៀវភៅផ្សព្វផ្សាយនេះជាលើកទីពីរ អោយមានតម្លាភាពនិងអព្យាក្រឹតភាពសំរាប់មេភូមិធ្វើការចែកប័ណ្ណព័តិមានជាលើកទីពីរចាប់ពីថ្ងៃទី ៨ ខែ កុម្ភៈ នេះរហូតដល់ថ្ងៃទី ៨ ខែ មិនា ឆ្នាំ ២០០៧ ។ លោក ក៏បានសុំអនុញ្ញាតិជំរាបជូនទៅដល់លោកប្រធាន PEC និងអង្គប្រជុំទាំងអស់ថា ជារៀងរាល់ខែអង្គការ UNDP បានរៀបចំអង្គប្រជុំមួយ ថ្នាក់ឯកអគ្គរាជទូត ដែលនៅក្នុងអង្គប្រជុំនេះ គ.ជ.ប ត្រូវធ្វើការរាយការណ៏ពីដំណើរការ និងលទ្ធផលការងាររបស់ខ្លួនទៅដល់ថ្នាក់ទូតទាំងអស់ ជាពិសេសចំពោះបញ្ហាប័ណ្ណព័ត័មាននេះពួកគាត់មានការចាប់អារម្មណ៏ខ្លាំង ដោយមានការតិះទៀនកែលំអរនិងសសើរនៅពេល ដែលចេញជាសៀវភៅបទណែនាំនេះដោយផ្តល់ជាជំនួយថវិកាជាបន្តបន្ទាប់ដើម្បីជំរុញការងារនេះអោយកាន់តែល្អប្រសើរឡើង ហើយអ្វីដែលការប្រជុំថ្នាក់ជាតិធ្វើការប្រជុំជជែកពិភាក្សានេះ ក៏យកទៅរាយការណ៏ទៅសហគមន៏អន្តរជាតិតាមរយះ

អង្គទូតនានាដែលមកប្រជុំនៅអង្គការ UNDP រាល់ខែនោះដែរ យ៉ាងណាមិញអង្គការ ឬសហគមន៍អន្តរជាតិ ក៏បានធ្វើការសសើរដល់យន្តការខប់សែល នេះ ដែលវាជាមោទនៈភាពមួយសំរាប់ជាតិខ្មែរ ។

លោក **បាន សម្ពី** ជាសមាជិកក្រុមប្រឹក្សាឃុំកំពង់ក្តី គណៈបក្ស សម រង្ស៊ី បានបង្ហាញពីការព្រួយបារម្ភខ្លះៗអំពីសៀវភៅដែលបានឧបត្ថមដោយអង្គការក្រៅរដ្ឋាភិបាលហើយដែល គ.ជ.ប បានបោះពុម្ព និងបង្ហាញពីបទបញ្ញត្តិ និងនីតិវិធីនៃការបោះឆ្នោតមួយចំនួននៅក្នុងសៀវភៅនោះ ដូចនេះ លោក សុំសួរថា ប្រសិនបើមានបុគ្គលណាមួយបំពានលើច្បាប់នោះ តើក្រុមប្រឹក្សាឃុំសង្កាត់ ឬក៏គណកម្មាការឃុំ-សង្កាត់ រៀបចំការបោះឆ្នោតជាអ្នកចាត់វិធានការ ឬ ក៏មានយន្តការណាមួយផ្សេងទៀតដែលមានតួនាទីក្នុងការការពារ និងរក្សាដំណើរការនៃការបោះឆ្នោតទប់ស្កាត់នូវការបំពានទាំងឡាយ? លោក ក៏បានបន្ថែមថា ប្រសិនបើមាននរណាម្នាក់ជាមន្ត្រីរាជការក្តី ជាសមាជិកក្រុមប្រឹក្សាឃុំក្តី ជាពិសេសមេភូមិ អនុប្រធានភូមិ ជំនួយការភូមិដែលគេទើបតែបោះឆ្នោតអោយថ្មីៗបានអនុវត្តខុស នេះជាការពិបាកក្នុងការពិន័យណាស់ព្រោះថា ពួកគាត់ជាអ្នកដែលធ្វើការងារជាមួយ លោក ដូចពាក្យស្លោកនិយាយថា បើយល់ញាតិឃ្លាតច្បាប់ បើយល់ច្បាប់នោះប្រាកដជាឃ្លាតញាតិ ។

លោក **ឈើយ ឈឿម** ជំទប់ទី២ ឃុំស្វាយដង្គំស្រុកសៀមរាបមកពីគណបក្សសម រង្ស៊ី បានមានប្រសាសន៍ផ្តោតសំខាន់ទៅលើចំនុច៤ ទី១ គឺលោកសុំសួរទៅប្រធាន គ.ជ.ប ខេត្តពីបញ្ហាអ្នកដែលបាត់ឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតដែលពួកគាត់បាន ទៅចុះឈ្មោះហើយ និងមានប័ណ្ណបោះឆ្នោតត្រឹមត្រូវ ឥលូវនេះពួកគាត់ទាមទារសិទ្ធិបោះឆ្នោតរបស់គាត់ តើអ្នកណាជាអ្នកទទួលខុសត្រូវចំពោះបញ្ហានេះ? ជាពិសេសពួកគាត់មានសាក្សីដឹងឮ គ្រាប់គ្រាន់ទៀត ដូច្នេះតើផ្នែកច្បាប់ដោះស្រាយយ៉ាងណាដែរ? ទី២ លោក សូមជំរាបទៅប្រធាន គ.ជ.ប ខេត្តអោយបានជ្រាបអំពីឃុំនរគធំដែលប្រជាជនចុះឈ្មោះហើយពុំមានទំរង់ ១០១៨ទេ ប៉ុន្តែគាត់ មានប័ណ្ណតែមិនមែនជាអត្តសញ្ញាណប័ណ្ណ ដូចនេះ លោក ក៏បានស្នើសុំអោយ គ.ជ.ប ធ្វើការចាប់អារម្មណ៍និងចាត់វិធានការដោះស្រាយពី ព្រោះលោកមានការព្រួយបារម្ភថា ប្រជាជននៅក្នុងភូមិនោះពុំមានសិទ្ធិអាចទៅបោះឆ្នោតបាន ។ ទី៣ លោកស្នើសុំអោយមានទីតាំងការិយាល័យនៅឆ្ងាយពីផ្លូវថ្នល់បន្តិចដើម្បីសំរួលការធ្វើចរាចរអោយងាយស្រួលនិងជៀសវាងជំលោះគណបក្សផ្សេងៗ ។ ទី៤ ពាក់ព័ន្ធបញ្ហា CEC គឺលោកសូមឱ្យ គ.ជ.ប បណ្តុះបណ្តាបន្ថែមទៀតដល់ខាង CEC ព្រោះចំនេះដឹងរបស់ CEC នៅមានកំរិតទាបណាស់ ។

លោក **នឹម វ៉ាន់សំ** បានលើកនូវដំណោះស្រាយមួយចំនួនដូចតទៅ: សំរាប់សំនួររបស់ លោក ហេង លី ពាក់ព័ន្ធនូវបញ្ហាម៉ាស៊ីនថត លោក បានជំរាបថា ការស្នើសុំនេះត្រូវមើលតាមថវិការបស់ គ.ជ.ប សិន ព្រោះថា ម៉ាស៊ីនថតប្រភេទនេះមានតំលៃខ្ពស់ណាស់ហើយ បើតាមបទពិសោធន៍កន្លងមកឃើញថា ការប្រើម៉ាស៊ីនថតកន្លងមកមានបញ្ហាច្រឡំគ្នាច្រើនសរុបមក លោក ពុំទាន់ហ៊ានសំរេចទេចំពោះបញ្ហានេះ ព្រោះត្រូវការថវិកាច្រើនណាស់ទាំងថវិកាជាតិផង និងថវិកាជំនួយផងដែរ ។ ចំពោះការចែកប័ណ្ណពតិមាននៅខេត្តសៀមរាបនេះ លើកទី១ បានចំនួន ៧៧.៥៦% នៃប្រជាពលរដ្ឋដែលមានឈ្មោះបោះឆ្នោតទាំងអស់ ហើយភាគច្រើនបានទៅដល់ស្រុកដែលឆ្ងាយៗ រីឯនៅក្នុងស្រុកសៀមរាបតែម្តងមានការពិបាកក្នុងការចែកជូនណាស់ ត្បិតពួកគេតែងតែមមាញឹក នឹងការងារច្រើនជាហេតុពិបាកជួបគ្នាតែទោះជាយ៉ាងណាលើកទី២ នេះ PEC នឹងព្យាយាមចែកជូនអោយបានគ្រប់ៗគ្នាតាមមធ្យោបាយ ផ្សេងៗ ។ បញ្ហាអត្តសញ្ញាណប័ណ្ណដែលមិនទាន់ចេញនោះពិតជាការលំបាកក្នុងការដោះស្រាយណាស់ ដូច្នេះគេមានតែពឹងផ្អែកច្រើនទៅលើទំរង់ ១០១៨ ហើយប្រសិនបើអត្តសញ្ញាណប័ណ្ណបានចេញ ក៏មិនត្រូវពឹងផ្អែកតែប័ណ្ណនេះមួយបានទេ តែត្រូវពិនិត្យមើលទៅលើប័ណ្ណពតិមានឬលិខិតចំបាច់ទាំងអស់ដើម្បីចៀសវាងការក្លែងបន្លំ និងកំហុសឆ្គងផ្សេងៗ ។

ឆ្លើយនូវសំណួររបស់ លោក **បាន សម្តី** ពាក់ព័ន្ធនឹងការអនុវត្តខុសរបស់មេភូមិ រីឯជំនួយការភូមិថា រាល់បញ្ហាដែលកើតឡើងក្នុងដំណាក់ការចុះឈ្មោះបោះឆ្នោតទាំងអស់មានក្រុមប្រឹក្សាឃុំជាអ្នកចាត់វិធានការណ៍ដោះស្រាយព្រោះ គ.ជ.ប បានប្រគល់អំណាចទៅខាងឃុំ ដោយឡែកក្នុងដំណាក់ការបោះឆ្នោត មានគណកម្មាការឃុំជាអ្នកដោះស្រាយ បន្ទាប់មកមានគណកម្មាការខេត្ត គណកម្មាការជាតិរៀបចំការបោះឆ្នោត និងក្រុមប្រឹក្សាធម្មនុញ្ញតាមឋានានុក្រម ។ ទាក់ទងនឹងសំនួររបស់លោក **ឈឿយ ឈឿម** លោក សូមជំរាបថា តាមច្បាប់កាលណាបើសិនជាគ្មានឈ្មោះនៅក្នុងបញ្ជីនោះទេមិនអាចមានសិទ្ធិបោះឆ្នោតនោះទេ ព្រោះនៅពេលចុះឈ្មោះហើយគេ នឹងបិទបញ្ជីដំបូងដែលស្មៀនចុះដោយដៃបូកនឹងបញ្ជីឆ្នាំ ២០០៥ ដែលគេលុបឈ្មោះអ្នកស្លាប់បច្ចុប្បន្នភាពជាមួយគ្នា ហើយពេលនោះគេអោយប្រជាពលរដ្ឋមានសិទ្ធិទៅមើលឈ្មោះក្នុងគោលបំណងទុកសិទ្ធិអោយប្រជាពលរដ្ឋប្តឹងផ្តល់ ប្រសិនបើមិនឃើញឈ្មោះរបស់ខ្លួន ប្រសិនបើប្រជាពលរដ្ឋមិនបានតវ៉ានៅក្នុងកំឡុងពេលនោះទេ បញ្ជីឈ្មោះបោះឆ្នោតនោះចាត់ទុកជា សុពលភាពហើយ ។ ចំពោះបញ្ហាមួយទៀតអំពីទំរង់ ១០១៨ ដែលប្រជាពលរដ្ឋពុំមាននោះ គណកម្មាការឃុំអាចជួយធ្វើឱ្យពួកគាត់ ដើម្បីមានសិទ្ធិទៅបោះឆ្នោតជាធម្មតាបានព្រោះមិនទាន់ហួសពេលកំណត់ទេ ។ រីឯបញ្ហាទីតាំងរបស់ការិយាល័យ លោក នឹងបញ្ជាក់ថាខាងលោក ឱ្យពិនិត្យមើលឡើងវិញប៉ុន្តែវាក៏ជាការលំបាកដែរក្នុងការផ្លាស់ប្តូរទីតាំងនេះដោយសារនេះជាគោលការណ៍របស់ គ.ជ.ប ជាពិសេសវាបង្កនូវការលំបាកសំរាប់ប្រជាពលរដ្ឋរកមិនឃើញការិយាល័យបោះឆ្នោត ។ លោក បានបញ្ជាក់បន្ថែមថា លោក នឹងព្យាយាមបណ្តុះបណ្តាល CEC របស់ លោក អោយបានច្រើនជាងមុន និងអញ្ជើញគ្រូបង្គោលទៅបណ្តុះបណ្តាលនៅ គ.ជ.ប ទៀត ដើម្បីបង្កើនសមត្ថភាព CEC របស់ លោក ទិសដៅជំរុញអោយការងារកាន់តែប្រសើរឡើង ។

លោក **ឱក សេរី សោភក្តិ** តំណាងវិទ្យាស្ថាន CDRI និងជាតំណាងទីប្រឹក្សារបស់ UNDP បានមានប្រសាសន៍បិទអង្គប្រជុំដោយធ្វើសេចក្តីថ្លែងអំណរគុណដល់អង្គប្រជុំទាំងអស់ ហើយ លោក ក៏បង្ហាញនូវទឹកចិត្តសប្បាយរីករាយនិងកោតសសើរដល់ការចូលរួមពិភាក្សាផ្លោះប្តូរយោបល់ដោយអាកប្បកិរិយាថ្លៃថ្នូរបំផុត ជំរុញអោយអង្គប្រជុំនេះដំណើរការបានយ៉ាងរលូន និងទទួលបានលទ្ធផលគួរជាទីគាប់ប្រសើរ សក្តិសម នឹងការចំណាយថវិកាដោយពុំមានការសោកស្តាយឡើយ ដែលទាំងនេះបង្ហាញអោយឃើញថាប្រទេសកម្ពុជាកំពុងតែឈានទៅរកភាពចាស់ទុំនៃថ្នាក់នយោបាយក្នុងការអនុវត្តលទ្ធិប្រជាធិបតេយ្យដែលធ្វើអោយមានមោទនភាពជាពន្លឹក ។ ជាទីបញ្ចប់ លោក ក៏សូមបួងសួងដល់ព្រះរតនៈត្រៃ និងទេវតារក្សាស្វេតឆ័ត្រ ជួយថែរក្សាទឹកដីប្រទេសកម្ពុជា ជាពិសេសសម្បត្តិកេរ៍តំណែលវប្បធម៌របស់យើង គឺប្រាសាទអង្គរ ហើយសូមឱ្យ អស់លោក លោកស្រីទាំងអស់អោយបានប្រកបតែ ពុទ្ធពរទាំង៥ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈកុំបីឃ្លៀងឃ្លាតឡើយ ។